***Justification***

Copyright © 2012 by The Gospel Coalition

Published by Crossway
a publishing ministry of Good News Publishers
Wheaton, Illinois 60187, U.S.A.

This edition published by arrangement with Crossway.
All rights reserved.

This project was accomplished in partnership with The Gospel Coalition International Outreach.

# ការរាប់ជាសុចរិត

លោក ភីលីព ក្រាហាំ រីខែន Philip Graham Ryken

មាតិកា


មនុស្សទាំងអស់ត្រូវការព្រះជាម្ចាស់រាប់គេជាសុចរិត ....... 2

សារៈសំខាន់របស់ការរាប់ជាសុចរិត: «គ្រឹះ» «ថ្មាំងមេ» ....... 4

អត្ថន័យរបស់ការរាប់ជាសុចរិត ....... 5

ប្រភពនៃការរាប់ជាសុចរិត: ព្រះគុណបានដោយទទេរបស់ព្រះ ....... 6

មូលដ្ឋានគ្រឹះសម្រាប់ការរាប់ជាសុចរិត៖ ជីវិតដ៏ឥតខ្ចោះនិងការសុគតជាយញ្ញបូជារបស់ព្រះយេស៊ូវ ....... 8

សេចក្តីសុចរិតនៃការរាប់ជាសុចរិត៖ ការផ្ទេរឲ្យបីដង ....... 10

ឧបករណ៍របស់ការរាប់ជាសុចរិត៖ សេចក្តីជំនឿក្នុងព្រះគ្រីស្ទ ....... 12

គោលដៅរបស់ការរាប់ជាសុចរិត៖ ការប្រព្រឹត្តល្អដើម្បីសិរីរុងរឿងរបស់ព្រះ ....... 15

ពួកអ្នកទទួលបានការរាប់ជាសុចរិត៖ មនុស្សដូចជាយើង ....... 16

កំណត់ ....... 17


សូមគិតក្នុងមនោគតិអំពីរូបភាពនេះៈ ឧក្រិដ្ឋជនដែលគេបានចោទប្រកាន់ម្នាក់ឈរនៅចំពោះចៅក្រមមិនលំអៀងដើម្បីទទួលការកាត់ទោសតាមយុត្តិធម៌របស់គាត់។ បណ្តឹងតាមផ្លូវច្បាប់ចាប់ផ្តើមដោយមានមន្ត្រីតុលាការសូត្រច្បាប់របស់ប្រទេស។ នៅពេលគាត់ស្តាប់ ឧក្រិដ្ឋជនបានដឹងខ្លួនថា គាត់នឹងត្រូវតុលាការកាត់ទោស ពីព្រោះគាត់បានល្មើសគ្រប់ច្បាប់ទាំងអស់។ មិនថាការចោទប្រកាន់ជាអ្វីនោះទេ គឺគាត់ពិតជាមានទោស។ នៅពេលចៅក្រមសួរចុងចោទថាគាត់ឆ្លើយតបទៅនឹងការចោទប្រកាន់នោះយ៉ាងម៉េច គាត់នៅស្ងៀម។ គាត់ឈរចំពោះមុខចៅក្រមដោយសេចក្តីតក់ស្លុតមិននិយាយស្តី មិនអាចនិយាយអ្វីដើម្បីការពារខ្លួនរបស់គាត់បាននោះឡើយ។

## *មនុស្សទាំងអស់ត្រូវការព្រះជាម្ចាស់រាប់គេជាសុចរិត*

ជំពូកដំបូងក្នុងកណ្ឌគម្ពីររ៉ូមបានពណ៌នាអំពីស្ថានការណ៍តាមផ្លូវច្បាប់ដែលអស់សង្ឃឹមដូចខាងលើ។ មនុស្សជាតិឈរក្នុងកន្លែងអ្នកទោសនៅពេលកាត់សេចក្តីហើយព្រះជាម្ចាស់នឹងវិនិច្ឆ័យគ្រប់មនុស្សជាតិទាំងអស់ ទាំងអ្នកកាន់តាមសាសនា និងអ្នកមិនមានសាសនា ទាំងពួកយូដានិងពួកសាសន៍ដទៃ ទាំងអ្នកជឿនិងអ្នកមិនជឿថាមានព្រះផង។ ខ្នាតគំរូសម្រាប់យុត្តិធម៌គឺជាក្រឹត្យវិន័យដ៏ឥតខ្ចោះរបស់ព្រះជាម្ចាស់។ យោងតាមខ្នាតគំរូនោះ គ្រប់គ្នាសមនឹងជាប់មានទោស។ «ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ» (រ៉ូម ៣:២៣) «គ្មានអ្នកណាសុចរិតសោះសូម្បីតែម្នាក់ក៏គ្មានផង» (រ៉ូម ៣:១០ ប្រៀបធៀបទំនុកដំកើង ១៤:៣)។[១]

ដូច្នេះ នៅពេលច្បាប់ត្រូវបានអាន នោះក្រឹត្យវិន័យនីមួយៗគឺជាការចោទប្រកាន់មួយ។ គ្មានអ្វីដែលយើងអាចនិយាយដើម្បីអះអាងថាយើងគ្មានទោសនោះឡើយ។ រីឯគ្រប់ទាំងសេចក្តីដែលក្រិត្យវិន័យបង្គាប់ នោះយើងដឹងថាបង្គាប់ដល់តែពួកអ្នកដែលនៅក្នុងបន្ទុកក្រិត្យវិន័យទេ ដើម្បីឱ្យគ្រប់ទាំងមាត់ត្រូវបិទ ហើយឱ្យលោកិយទាំងមូលជាប់មានទោសនៅចំពោះព្រះ ហេតុនោះបានជាគ្មានមនុស្សណាបានរាប់ជាសុចរិតនៅចំពោះទ្រង់ដោយអាងការប្រព្រឹត្តតាមក្រិត្យវិន័យនោះឡើយ ដ្បិតក្រិត្យវិន័យគ្រាន់តែសំដែងឱ្យស្គាល់អំពើបាបប៉ុណ្ណោះ (រ៉ូម ៣:១៩-២០)។

បញ្ហារបស់មនុស្សជាតិគឺជាអំពើបាប។ យើងគឺជាពួកមនុស្សបាបដែលមានទោសសមតែនឹងទទួលសេចក្តីក្រោធរបស់ព្រះប៉ុណ្ណោះហើយយើងក៏មិនអាចធ្វើអ្វីសោះដើម្បីសង្គ្រោះខ្លួនឯងបាន។ ក្រឹត្យវិន័យសុចរិតរបស់ព្រះមិនអាចសង្គ្រោះយើងបានទេ គឺមានតែកាត់ទោសយើងពីព្រោះយើងមិនអាចកាន់តាមក្រឹត្យវិន័យទាំងនោះបាន។ ដូច្នេះ នៅពេលយើងឈរនៅចំពោះការវិនិច្ឆ័យ ព្រះមិនអាចទទួលយកយើងដោយផ្អែកលើអ្វីៗដែលយើងបានធ្វើនោះទេ។ នេះជាការវិនិច្ឆ័យទោសដែលដឹងថាយើងមានទោសរួចទៅហើយ ហើយយើងត្រូវតែនៅមានទោសរហូតដល់ព្រះប្រកាសថាយើងសុចរិត។

មានតែពេលយើងទទួលស្គាល់ស្ថានភាពអស់សង្ឃឹមរបស់យើងចេញពីទស្សនៈតាមផ្លូវច្បាប់ប៉ុណ្ណោះដែលយើងអាចចាប់ផ្តើមយល់អំពីគោលលទ្ធិតាមព្រះគម្ពីរអំពីការរាប់ជាសុចរិត។ ជីវិតរបស់លោក ដូណាល់ ស្មាតតូ Donald Smarto ផ្តល់ឧទាហរណ៍ដ៏ល្អមួយអំពីការអស់សង្ឃឹមរបស់មនុស្សមានបាប។ ពេលកំពុងសិក្សាធ្វើជាសង្ឃ លោកស្មាតតូ បានដើរតួជាកាឌីណាល់(អ្នកដឹកនាំខាងសាសនា)នៅក្នុងល្ខោនសាសនាមួយ។ កុដិគ្រីស្ទបរិស័ទ(អាស្រម) របស់គាត់បានរៀបចំឲ្យគាត់ខ្ចីអាវវែងដែលមានការតុបតែងយ៉ាងល្អពីអភិបាលដ្ឋានរបស់គាត់ដើម្បីជួយឲ្យគាត់មើលទៅកាន់តែដូចជាកាឌីណាល់ម្នាក់។ លោក ស្មាតតូសរសេរក្នុងស្វ័យជីវប្រវត្តិរបស់គាត់ថា «ការនេះធ្វើឲ្យខ្ញុំរំភើប ហើយពេលសំលៀកបំពាក់ទាំងនោះបានមកដល់ ខ្ញុំបានចូលក្នុងបន្ទប់របស់ខ្ញុំហើយចាក់សោហើយបានយកអាវវែងពណ៌ក្រហមខ្សែក្រវាត់ និងសំពត់គ្របស្មាចេញពីវ៉ាលីខោអាវដោយប្រយ័ត្នប្រយែង»។[២]

នៅពេលលោក ស្មាតតូ ស្លៀកសំលៀកបំពាក់ទាំងនេះមុនរាល់ការសំដែងល្ខោនពេលយប់ សំលៀកបំពាក់ទាំងនេះបានក្លាយជាការគិតមមៃកាន់តែខ្លាំងឡើងៗ៖

> ថ្វីបើល្ខោនបានចាប់ផ្តើមនៅម៉ោងប្រាំបីក៏ដោយ ក៏ខ្ញុំបានស្លៀកអាវវែងកាន់តែមុនពេលទៅៗ។ ខ្ញុំចំណាយពេលប្រហែលកន្លះម៉ោងដើម្បីបិទឡេវទាំងអស់ ប៉ុន្តែប៉ុន្មានថ្ងៃចុងក្រោយនៃការសំដែង ខ្ញុំបានស្លៀកពាក់នៅម៉ោងពីររសៀល គឺប្រាំម៉ោងមុនការចាប់ផ្តើមល្ខោន។ ខ្ញុំបានដើរពើងទ្រូងចុះឡើងនៅមុខកញ្ចក់វែងមួយ។ ខ្ញុំបានឈរអស់ពេលជាយូរសំឡឹងមើលរូបរបស់ខ្ញុំ ហើយខ្ញុំបានចូលចិត្តអ្វីដែលខ្ញុំបានមើលឃើញក្នុងកញ្ចក់នោះ...ខ្ញុំបានមានអារម្មណ៍ថា ខ្ញុំបរិសុទ្ធ។ ខ្ញុំមិនបានគិតថា ខ្ញុំគឺជាមនុស្សមានបាបនោះទេ គឺខ្ញុំបានមានទំនុកចិត្តថា ការងាររបស់ខ្ញុំបានផ្គាប់ព្រះហឫទ័យព្រះ។[៣]

នៅពេលគាត់បានមើលឃើញមនុស្សនៅខាងក្នុងអាវវែង (ខ្លួនគាត់) ពិតជានរណានោះ ទំនុកចិត្តខុសរបស់លោក ស្មាតតូ ត្រូវរលាយ។

គាត់បានមើលខ្សែភាពយន្តមួយដែលមានអភិបាលម្នាក់បានឡើងមកលើឆាក។ អភិបាលបានដើរចេញយឺតៗពីខាងក្រោយវាំងននដោយស្លៀកសំលៀកបំពាក់ផ្លូវការយ៉ាងស្អាតដែលមានត្បូងមានពន្លឺភ្លឺផ្លេកៗ។ តែពេលគាត់បានដើរ នោះមានខ្យល់បក់យ៉ាងខ្លាំងធ្វើឲ្យរបើកសំលៀកបំពាក់ផ្លូវការរបស់គាត់ ហើយធ្វើឲ្យគេមើលឃើញគ្រោងឆ្អឹងពុកផុយពីខាងក្រោម។

> ខណៈនោះ គំនិតរបស់ខ្ញុំបាននិយាយថា គឺជារូបខ្ញុំ.....ភ្លាមនោះខ្ញុំបានបិទគំនិតរបស់ខ្ញុំ....ខ្ញុំបាននិយាយថា 'មិនមែនជារូបខ្ញុំទេ!"...ខ្ញុំចង់យករូបភាពខ្សែភាពយន្តនោះចេញពីគំនិតរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនអាចធ្វើបាន...ខ្ញុំបានខំធ្វើឲ្យ

អារម្មណ៍ខ្លួនឯងបានល្អប្រសើរ។ ខ្ញុំបាននិយាយទៅកាន់ព្រះថា 'សូមធ្វើឲ្យអារម្មណ៍នេះចេញឆ្ងាយពីទូលបង្គំទៅ"។ ខ្ញុំមិនមែនជាមនុស្សកំពុកនោះទេ។ ខ្ញុំគឺជាមនុស្សល្អម្នាក់! ខ្ញុំបានខិតខំគិតអំពីការល្អទាំងអស់ដែលខ្ញុំបានធ្វើ....ប៉ុន្តែគំនិតទាំងនេះមិនបានធ្វើឲ្យខ្ញុំបានធូរស្បើយសោះ។[៤]

មានតែពេលដែលយើងមើលឃើញសេចក្ដីពិតដ៏អាក្រក់អំពីអំពើបាបរបស់យើងទេដែលយើងត្រៀមខ្លួនជាស្រេចដើម្បីងាកបែរមកទទួលយកជំនួយពីព្រះ ដែលជាសេចក្ដីអត់ទោសនិងសេចក្ដីសុចរិតរបស់ព្រះយេស៊ូវគ្រីស្ទ។ លោក យ៉ាកុប ប៊ុឆាណាន James Buchanan បានសរសេរអំពីការរាប់ជាសុចរិតនៅក្នុងសៀវភៅល្បីល្បាញរបស់គាត់ថា «ការត្រៀមល្អបំផុតសម្រាប់ការសិក្សាគោលលទ្ធិអំពីការរាប់ជាសុចរិតមិនមែនជាសមត្ថភាពវៃឆ្លាតដ៏អស្ចារ្យ ឬជាការរៀនខាងវិជ្ជាជ្រៅជ្រះខ្លាំងនោះទេ ប៉ុន្តែវាគឺជាបញ្ញាចិត្តមួយដែលយល់អំពីលក្ខខណ្ឌរបស់យើងជាពួកមនុស្សមានបាបនៅចំពោះព្រះនេត្ររបស់ព្រះ»។[៥]

## *សារៈសំខាន់របស់ការរាប់ជាសុចរិត: «គ្រឹះ» «ថ្នាំងមេ»*

បន្ទាប់ពីការពិពណ៌នាអំពីស្ថានការណ៍អាក្រក់របស់យើងជាមនុស្សមានបាប សាវ័កប៉ុលប្រកាសថា យើងអាចរកដំណោះស្រាយតាមផ្លូវច្បាប់បាន «ប៉ុន្តែឥឡូវនេះ ក្រៅពីក្រឹត្យវិន័យ សេចក្ដីសុចរិតផងព្រះដែលមានទាំងក្រឹត្យវិន័យ និងពួកហោរាធ្វើបន្ទាល់ឲ្យផងនោះបានលេចចេញមកហើយ» (រ៉ូម ៣:២១)។ ពាក្យថា «ប៉ុន្តែឥឡូវនេះ» ជាសេចក្ដីភ្ជាប់ដ៏សំខាន់នៅក្នុងការពិភាក្សារបស់លោកប៉ុល។ លើសពីនេះ ពាក្យនេះនែនាំអំពីពេលដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រនៃសេចក្ដីសង្គ្រោះ។ មកដល់សញ្ញាថ្មីយើងនៅតែជាប់មានទោស។ ក្រឹត្យវិន័យដ៏ឥតខ្ចោះរបស់ព្រះប្រាប់យើងថា គ្មានអ្នកណាអាចប្រកាសថាយើងសុចរិតនៅចំពោះយុត្តិធម៌របស់ព្រះបានឡើយ។ ប៉ុន្តែឥឡូវនេះ សេចក្ដីសុចរិតរបស់ព្រះត្រូវបានបើកសំដែងហើយ។ ព្រះបានប្រទានផ្លូវដល់យើងដើម្បីឲ្យព្រះបានប្រកាសថា យើងសុចរិត។ ឬយើងនិយាយតាមពាក្យក្នុងព្រះគម្ពីរថា ទ្រង់បានប្រទានផ្លូវមួយដើម្បីឲ្យព្រះបានរាប់យើងជាសុចរិត។

សេចក្ដីសង្គ្រោះមានន័យលើសជាងការរាប់ជាសុចរិតតាមរយៈសេចក្ដីជំនឿទៅទៀត។ ប៉ុន្តែដោយមិនបំផ្លើសសារៈសំខាន់របស់វានោះទេ នោះយើងត្រូវតែនិយាយថា គោលលទ្ធិនេះគឺនៅជិតទីកណ្ដាលរបស់ដំណឹងល្អ។ ការរាប់ជាសុចរិតគឺជាផ្ទៃរឿងកណ្ដាលមួយរបស់ព្រះគម្ពីរ ជាពិសេសព្រះគម្ពីរសញ្ញាថ្មី ដូច្នេះទម្រង់ពាក្យ «រាប់ជាសុចរិត» *(dikaio)*លេចឡើងចំនួនលើសជាងពីរយដង។[៦]នេះបង្ហាញអំពីសារៈសំខាន់របស់ការរាប់ជាសុចរិតនៅក្នុងទេវសាស្ត្រតាមព្រះគម្ពីរ។

សារៈសំខាន់របស់ការរាប់ជាសុចរិតត្រូវបានទេវវិទូនៅក្នុងប្រវត្តិសាស្ត្រពួកជំនុំទទួលស្គាល់។ បណ្ឌិត ចន កាលវិន (John Calvin) បានហៅវាថា «ត្រចៀកទ្វារមេដែលធ្វើឲ្យសេចក្ដីសង្គ្រោះបិទបើកបាន»។[៧] អ្នកកំណែទម្រង់ជនជាតិអង់គ្លេស លោក ថូម៉ាស គ្រេនមើរ Thomas Cranmer បានពិពណ៌នាអំពីវាថាជា «ថ្មដានិងគ្រឹះនៃសាសនារបស់គ្រីស្ទបរិស័ទ»។[៨] ប្រហែលជាល្បីល្បាញបំផុតដែលបណ្ឌិត ម៉ាទីន លូធើរ (Martin Luther) បានហៅការរាប់ជាសុចរិតថា «ថ្នាំងមេនៃគោលលទ្ធិគ្រីស្ទបរិស័ទ» គឺថា «នៅពេលការរាប់ជាសុចរិតបានធ្លាក់ចុះ គ្រប់យ៉ាងក៏បានធ្លាក់ចុះដែរ»។[៩] មិនថាយើងគិតថាការរាប់ជាសុចរិតជាត្រចៀក គ្រឹះ ឬថ្នាំងនៃសេចក្ដីសង្គ្រោះដែលនាំឲ្យគ្រប់យ៉ាងគង់នៅឬការបាត់បង់ បើព្រះជាម្ចាស់មិនរាប់យើងជាសុចរិតទេ នោះយើងគ្មានសេចក្ដីសង្ឃឹមថា ព្រះអង្គនឹងសង្គ្រោះយើងនោះទេ ។ ក្នុងឱកាសមួយទៀត បណ្ឌិត ម៉ាទីន លូធើរបាននិយាយថា នេះគឺជាគោលលទ្ធិដែល «បង្កើត ផ្គត់ផ្គង់ ស្អាងចិត្ត រក្សា និងការពារពួកជំនុំរបស់ព្រះ ហើយបើគ្មានការរាប់ជាសុចរិតនោះទេ នោះពួកជំនុំរបស់ព្រះមិនអាចមាននៅបានមួយម៉ោងផង»។[១០]

# *អត្ថន័យរបស់ការរាប់ជាសុចរិត*

ការរាប់ជាសុចរិតសំខាន់ចំពោះដំណឹងល្អគ្រីស្ទបរិស័ទ ពីព្រោះវាឆ្លើយតបនឹងសំនួរគ្រឹះដែលសួរថា «តើមនុស្សមានបាបអាចត្រឡប់ជាសុចរិតនៅចំពោះព្រះដ៏បរិសុទ្ធបានយ៉ាងដូចម្ដេច?»ចម្លើយមានក្នុងសេចក្ដីបង្រៀនតាមព្រះគម្ពីរអំពីការរាប់ជាសុចរិត ដែលសេចក្ដីថ្លែងការណ៍អំពីសេចក្ដីជំនឿរបស់ក្រុមចម្រុះដំណឹងល្អផ្ដល់អត្ថន័យដូចតទៅ៖

> យើងជឿថាដោយសារការស្ដាប់បង្គាប់និងការសុគតរបស់ទ្រង់ព្រះគ្រីស្ទបានបង់សងបំណុលទាំងស្រុងដល់អស់ពួកអ្នកដែលបានរាប់ជាសុចរិត។ដោយសារយញ្ញបូជាដែលទ្រង់ថ្វាយនោះទ្រង់បានទទួលទោសជំនួសយើងជាទោសដែលយើងត្រូវទទួលដោយសារអំពើបាបយើងដោយទ្រង់បានផ្ដាច់យ៉ាងត្រឹមត្រូវពិតប្រាកដហើយពេញលេញដល់សេចក្ដីយុត្តិធម៌របស់ព្រះជំនួសយើងរាល់គ្នា។ដោយសារការស្ដាប់បង្គាប់ដ៏គ្រប់លក្ខណ៍របស់ទ្រង់ព្រះយេស៊ូវបានបំពេញតាមការទាមទារដ៏សុចរិតរបស់ព្រះជំនួសយើងរាល់គ្នាដ្បិតដោយសារសេចក្ដីជំនឿតែម្យ៉ាងគត់ដែលព្រះរាប់អ្នកដែលបានទុកចិត្តលើព្រះគ្រីស្ទតែមួយអង្គគត់ដើម្បីឲ្យបានទទួលមកនៅជាមួយព្រះវិញថាជាការស្ដាប់បង្គាប់ដ៏គ្រប់លក្ខណ៍។

វាក្យស័ព្ទនៃការរាប់ជាសុចរិតមកពីតុលាការ ដែលមានកិរិយាសព្ទប្រកាស «រាប់ជាសុចរិត» គឺជាពាក្យច្បាប់ដែលសំដៅលើការប្រឈមរបស់មនុស្សម្នាក់ចំពោះតុលាការ។ ពាក្យផ្សេងៗតាមព្រះគម្ពីរសម្រាប់ការរាប់ជាសុចរិតមានដើមកំណើតទាក់ទងនឹងច្បាប់។ កិរិយាសព្ទភាសាក្រិក *dikaio* ដែលមានន័យថា «រាប់ជាសុចរិត» គឺជាពាក្យខាងច្បាប់ដែល «ប្រកាសអំពីការកាត់ឲ្យរួចពីទោស»។[១១]ដើម្បីរាប់ជាសុចរិតគឺត្រូវតែផ្ដល់ការវិនិច្ឆ័យប្រកាសថាមនុស្សម្នាក់ស្ថិតខាងត្រូវប្រកាសអំពីការអត់ទោសក្នុងពាក្យតាមផ្លូវច្បាប់។ ការរាប់ជាសុចរិតគឺជាការបង្ហាញថាគ្មានទោស។ វាគឺជាសេចក្ដីសម្រេចរបស់តុលាការដែលប្រកាសថា មនុស្សម្នាក់មានទំនាក់ទំនងត្រឹមត្រូវជាមួយព្រះនិងច្បាប់របស់ទ្រង់។វាគឺជាការប្រកាសថានៅក្រោមការវិនិច្ឆ័យរបស់ច្បាប់ចុងចោទមិនមានទោសនោះទេ ប៉ុន្តែលើកលែងទោស)។

របៀបល្អមួយដើម្បីឲ្យអត្ថន័យលើការរាប់ជាសុចរិតគឺប្រៀបធៀបនឹងពាក្យផ្ទុយរបស់វាគឺ ការជាប់មានទោស។ ដើម្បីផន្ទាទោសគឺត្រូវតែប្រកាសថា មនុស្សម្នាក់ទុច្ចរិត។ វាគឺជាសេចក្ដីសម្រេចរបស់តុលាការដែលច្បាប់ប្រកាសថា គាត់មានទោស។ ការពិត សកម្មភាពផន្ទាទោសនេះមិនមែនជាអ្វីដែលធ្វើឲ្យឧក្រិដ្ឋជនមានទោសនោះទេ។ សកម្មភាពផ្ទាល់របស់គាត់ទេដែលធ្វើឲ្យគាត់មានទោស ហើយគាត់មានទោសនៅពេលគាត់បានរំលោភច្បាប់។ ដូច្នេះ នៅពេលដែលគាត់ត្រូវបានផន្ទាទោស តុលាការប្រកាសអំពីអ្វីដែលគាត់បានជារួចទៅហើយ គឺមនុស្សបាបមានទោស។

ការរាប់ជាសុចរិតគឺផ្ទុយនឹងការផន្ទាទោស។ ដើម្បីរាប់ជាសុចរិតគឺត្រូវតែប្រកាសថា មនុស្សម្នាក់ត្រូវលើកលែងទោស។ ក្នុងការរាប់ជាសុចរិត មនុស្សម្នាក់មិនត្រូវបានធ្វើឲ្យក្លាយជាសុចរិតនោះទេ ប៉ុន្តែត្រូវបានគេប្រកាសថាសុចរិត។ ដូច្នេះ ការរាប់ជាសុចរិតមិនមែនជាដំណើរការមួយនោះទេ ប៉ុន្តែជាសកម្មភាពមួយ។ វាមិនមែនជាការប្រែប្រួលជីវិតរបស់យើងដើម្បីធ្វើឲ្យយើងមានជីវិតសុចរិតតាមរយៈសេចក្ដីជំនឿបូកនឹងការប្រព្រឹត្តនិងអត្តសញ្ញាគ្រីស្ទបរិស័ទ ដូចជាទេវវិទូខ្លះបានព្យាយាមអះអាងនោះឡើយ ប៉ុន្តែវាជាការដែលព្រះជាម្ចាស់ប្រកាសថាទ្រង់រាប់យើងជាសុចរិតតាមរយៈសេចក្ដីជំនឿតែមួយគត់។

ព្រះគម្ពីរអាចបង្ហាញអត្ថន័យពិតរបស់ការរាប់ជាសុចរិតជា «ការប្រកាសតាមផ្លូវច្បាប់ថា យើងសុចរិត» មិនមែនជា «ការធ្វើឲ្យយើងមានចរិតលក្ខណៈសុចរិត» នោះទេ។ ជាឧទាហរណ៍ ក្នុងចោទិយកថា ២៥:១ បង្រៀនថា «បើកាលណាមនុស្សកើតរឿងទាស់ទែងគ្នា ហើយគេប្ដឹងផ្ដល់ដល់ចៅក្រមឲ្យជំនុំជំរះក្ដីនោះ នោះត្រូវឲ្យចៅក្រមតាំងឲ្យអ្នកដែលសុចរិតបានជាសុចរិតចុះ ហើយកាត់ទោសដល់អ្នកដែលមានទោសវិញ»។ ច្បាស់លាស់ណាស់ថា ចៅក្រមមិនធ្វើឲ្យគាត់មានទោសនោះទេ គឺចៅក្រមគ្រាន់តែប្រកាសថាគាត់មានទោស ដោយហេតុនោះចៅក្រមផន្ទាទោសគាត់។ ពាក្យ «លើកទោស» (ដែលពិតជាកិរិយាសព្ទភាសាហេព្រើរ hatsdiq «រាប់ជាសុចរិត» មានន័យថា «ប្រកាសថាសុចរិត»។

ឬយើងពិចារណាលើសុភាសិត ១៧:១៥ «អ្នកណាដែលរាប់មនុស្សអាក្រក់ជាឥតមានទោស ហើយអ្នកណាដែលកាត់ទោសដល់មនុស្សសុចរិត អ្នកទាំងពីរនោះជាទីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា»។ ទីនេះម្តងទៀត ពាក្យថា «លើកទោស» ឬ «រាប់ជាសុចរិត» (hatsdiq) សំដៅយ៉ាងច្បាស់លាស់លើការប្រកាសតាមផ្លូវច្បាប់មួយ។ តាមរយៈការទួញសោកការរាប់អ្នកមានទោសជាសុចរិត ព្រះមិនកំពុងព្យាយាមបញ្ឈប់អ្នកមានទោសពីការផ្លាស់ប្រែឲ្យទៅជាពលរដ្ឋល្អនោះឡើយ។ បើសិនការរាប់អ្នកមានទោសជាសុចរិតមានន័យថា ធ្វើឲ្យពួកគេមានចរិតលក្ខណៈសុចរិត នោះព្រះប្រាកដជាចង់បាន!តែទ្រង់ជំទាស់នឹងការប្រកាសខុសថា អ្នកមានទោសត្រូវបាននិរទោស។

ព្រះគម្ពីរសញ្ញាថ្មីបានប្រើពាក្យរាប់ជាសុចរិតក្នុងរបៀបដូចគ្នា។ ដូចនៅក្នុងព្រះគម្ពីរសញ្ញាចាស់ នៅក្នុងសញ្ញាថ្មីរាប់ជាសុចរិតជាពាក្យផ្ទុយនិងកាត់ទោស។ ជាឧទាហរណ៍ច្បាស់លាស់ដែលប៉ុលបង្ហាញអំពីភាពផ្ទុយគ្នារវាងអំពើបាបរបស់អ័ដាមនិងអំណោយទានរបស់ព្រះគ្រីស្ទថា «ហើយអំណោយទាននោះ ក៏មិនមែនដូចជាអំពើបាប ដែលមនុស្សតែម្នាក់បានធ្វើនោះទៀត ដ្បិតសេចក្តីជំនុំជំរះ ដែលកើតមកដោយព្រោះម្នាក់នោះឯង នោះបានកាត់ទោសហើយ តែព្រះគុណ ដែលកើតមកដោយព្រោះការរំលងជាច្រើន នោះបានរាប់យើងទុកជាសុចរិតវិញ» (រ៉ូម ៥:១៦)។ ដូច្នេះ រាប់ជាសុចរិតមានន័យថា ប្រកាសថាចុងចោទម្នាក់គឺត្រូវលើកលែងទោសពការចោទប្រកាន់។ នៅពេលព្រះសង្គ្រោះយើង នោះទ្រង់ប្រកាសថា ទ្រង់អាចទទួលយកយើងបាននៅចំពោះទ្រង់ ហើយឥឡូវនេះយើងអាចឈរដោយគ្មានទាសនៅចំពោះទ្រង់។

ចូរកត់សំគាល់ថា ការរាប់ជាសុចរិតមានន័យលើសពីការលើកទោសទៅទៀត។ ដើម្បីរួចទោសគឺត្រូវតែប្រកាសថាមនុស្សម្នាក់ «មិនមានទោស»។ ប៉ុន្តែក្នុងការរាប់ជាសុចរិត ព្រះមិនគ្រាន់តែសំអាតមនុស្សមានបាបម្នាក់ចេញពីការចោទប្រកាន់ទាំងអស់នោះទេ ប៉ុន្តែទ្រង់ក៏ប្រកាសថា មនុស្សមានបាបម្នាក់សុចរិត។ ការរាប់ជាសុចរិតគឺជាការប្រកាសតាមផ្លូវច្បាប់ថា មនុស្សមានបាបម្នាក់សុចរិតដូចជាព្រះរាជបុត្រាស្ងួនភ្ងាររបស់ទ្រង់ផ្ទាល់ ដោយផ្អែកលើជីវិតឥតខ្ចោះនិងការសុគតជាយញ្ញបូជារបស់ព្រះយេស៊ូវគ្រីស្ទ។ព្រះជាម្ចាស់រាប់យើងជាសុចរិតដោយសារយើងជឿលើព្រះគ្រីស្ទ ដូច្នេះព្រះពរនេះផ្អែកលើអំពើរបស់ព្រះគ្រីស្ទ។

ទេវវិទូខ្លះបដិសេធថា ការនេះបានផ្តោតលើតុលាការខ្លាំងពេក។ ពួកគេបដិសេធចំពោះគំនិតដែលថា ឈើឆ្កាងគឺជាសកម្មភាពតាមផ្លូវច្បាប់មួយដែលជនរងគ្រោះដែលគ្មានទោសត្រូវសងសម្រាប់បទឧក្រិដ្ឋរបស់អ្នកដទៃ។ តែព្រះគម្ពីរបង្រៀនអំពីការរាប់ជាសុចរិតរបស់តុលាការ (តាមផ្លូវច្បាប់) ដោយមានហេតុផលត្រឹមត្រូវ។ ដោយសារមានរបៀបជាច្រើនដើម្បីបរិយាយអំពីព្រះគុណសង្គ្រោះរបស់ព្រះ នោះការរាប់ជាសុចរិតដែលជាសកម្មភាពតាមផ្លូវច្បាប់ គឺជាគ្រឹះសម្រាប់ដំណឹងល្អ។ ដោយសារព្រះគឺជាចៅក្រមនិងជាឪពុក នោះទំនាក់ទំនងរបស់យើងជាមួយទ្រង់ត្រូវតែជាទំនាក់ទំនងត្រឹមត្រូវមួយ។ ដកគ្រឹះតាមផ្លូវច្បាប់នេះ (ការរាប់ជាសុចរិត) គឺធ្វើឲ្យមនុស្សមានបាបម្នាក់មិនអាចស្គាល់ព្រះក្នុងផ្លូវសង្គ្រោះបាននោះទេ។ វាកាន់តែអាក្រក់ជាងនេះ បើសិនយើងដកគ្រឹះតាមផ្លូវច្បាប់នេះ នោះយើងជឿលើព្រះដែលមានសេចក្តីស្រលាញ់ដ៏អយុត្តិធម៌ដែលអត់ទោសមនុស្សដោយខ្លួនមិនមានសិទ្ធិធ្វើដូចនោះសោះ។

## *ប្រភពនៃការរាប់ជាសុចរិតៈ ព្រះគុណបានដោយទទេរបស់ព្រះ*

បើសិនសេចក្តីសុចរិតសំខាន់ចាំបាច់សម្រាប់ការរាប់ជាសុចរិត នោះតើវាមកពីណា?ដូចជាយើងបានឃើញហើយថាបញ្ហារបស់យើងគឺថា យើងមិនមានសេចក្តីសុចរិតរបស់ខ្លួនឯងនោះទេ។ ដូច្នេះ តើអ្វីជាប្រភពនៃការរាប់ជាសុចរិត?

ប្រភពនៃការរាប់ជាសុចរិតរបស់យើងគឺជាព្រះគុណដែលបានដោយទទេ។ សាវ័កប៉ុលនិយាយថា យើង «ដោយពឹងដល់ព្រះគុណទ្រង់ នោះបានរាប់ជាសុចរិតទទេ» (រ៉ូម ៣:២៤)។ សេចក្តីថ្លែងការណ៍អំពីសេចក្តីជំនឿរបស់ក្រុមចម្រុះដំណឹងល្អផ្តល់ចម្លើយទូលំទូលាយជាងថាៈ

ដោយព្រោះព្រះវរបិតាបានប្រទានព្រះគ្រីស្ទមកសម្រាប់យើងហើយក៏ទទួលយកនូវការស្តាប់បង្គាប់និងការរងទោសរបស់ទ្រង់ (ជាទណ្ឌកម្មដែលយើងរាល់គ្នាត្រូវទទួល)ដោយទទេហើយមិនមែនដោយសារអ្វីមួយចេញពីយើងរាល់គ្នាសោះនោះការរាប់ជាបរិសុទ្ធនេះគឺជាព្រះគុណដ៏សទ្ធាតែមួយប៉ុណ្ណោះប្រយោជន៍ឲ្យបានថ្វាយសិរីល្អដល់សេចក្តីយុត្តិធម៌និងព្រះគុណដ៏បរិបូណ៌របស់ព្រះក្នុងការដែលទ្រង់រាប់មនុស្សមានបាបជាសុចរិត។

ការនិយាយថា យើងបានរាប់ជាសុចរិតដោយសារព្រះគុណគឺជាការនិយាយថា ការរាប់ជាសុចរិតគឺធំលើសជាងអ្វីដែលយើងសមនឹងទទួលបាន។ វាគឺជាសកម្មភាពរបស់សេចក្តីល្អរបស់ព្រះដែលយើងមិនសមនឹងទទួលបាន។ លោក ថូម៉ាស ក្រេនមើរ Thomas Cranmer បានសរសេរនៅក្នុងសេចក្តីអធិប្បាយរបស់គាត់អំពីសេចក្តីសង្គ្រោះថា «គ្មានមនុស្សណាម្នាក់បានរាប់ជាសុចរិតនិងបានសុចរិតនៅចំពោះព្រះដោយសារការប្រព្រឹត្តរបស់ខ្លួនផ្ទាល់នោះទេ។ ប៉ុន្តែ មនុស្សគ្រប់រូបត្រូវតែស្វែងរកសេចក្តីសុចរិតឬការរាប់ជាសុចរិតមួយផ្សេងទៀតដែលយើងទទួលយកពីព្រះហស្តរបស់ព្រះ»។[១២] សារនៃដំណឹងល្អគឺថា ព្រះប្រទានសេចក្តីសុចរិតនេះដល់ពួកមនុស្សមានបាបជាអំណោយទាន «ដ្បិតគឺទ្រង់ហើយ ដែលទ្រង់រាប់គេជាសុចរិត» (រ៉ូម ៨:៣៣)។

ការនេះនាំឲ្យយើងមានជំលោះជាមួយការកាត់ស្រាយព្រះគម្ពីរសញ្ញាថ្មី។អំណោយទាននៃការរាប់ជាសុចរិតរបស់ព្រះត្រូវលើកឡើងពីរដងនៅក្នុងគម្ពីររ៉ូមជំពូក៣ ទាំងពីរដងនៅក្នុងខ.២១ («ប៉ុន្តែឥឡូវនេះ ក្រៅពីក្រឹត្យវិន័យ សេចក្តីសុចរិតផងព្រះដែលមានទាំងក្រឹត្យវិន័យ នឹងពួកហោរាធ្វើបន្ទាល់ឲ្យផង នោះបានលេចចេញមកហើយ») ហើយនឹងខ.២២ («គឺជាសេចក្តីសុចរិតរបស់ព្រះ»)។

មានរបៀបលើសពីមួយដើម្បីកាត់ស្រាយឃ្លានេះ។ ប្រហែលពាក្យ «របស់» ក្នុងឃ្លា «គឺជាសេចក្តីសុចរិតរបស់ព្រះ » គឺដូចគ្នាក្នុងឃ្លា «រាស្ត្ររបស់ព្រះ» ដែល «របស់» មានន័យថា មនុស្សជារបស់ព្រះ ហើយព្រះជាម្ចាស់ដែលពួកគេជារបស់។ ដូច្នេះ ប្រហែល «សេចក្តីសុចរិតរបស់ព្រះ» គឺជាសេចក្តីសុចរិតដែលព្រះមានហើយជារបស់ទ្រង់ដែលទ្រង់បង្ហាញក្នុងសេចក្តីសង្គ្រោះ។ យើងមើលឃើញគំនិតនេះនៅក្នុងទំនុកដំកើង ៩៨:២ និងក្នុងកន្លែងផ្សេងៗទៀត «ព្រះយេហូវ៉ាបានបើកសំដែងឲ្យស្គាល់សេចក្តីសង្គ្រោះរបស់ទ្រង់ ទ្រង់ធ្វើឲ្យសេចក្តីសុចរិតរបស់ទ្រង់បានប្រាកដច្បាស់នៅចំពោះភ្នែកនៃអស់ទាំងសាសន៍»។

ទោះយ៉ាងណា មានរបៀបកាត់ស្រាយមួយផ្សេងទៀត។ ពាក្យថា «របស់ព្រះ» អាចពន្យល់ថាសេចក្តីសុចរិតមកពីណា។ ឧទាហរណ៍ ឃ្លាថា «តន្ត្រីរបស់មៃខើល ចាកសាន់ Michael Jackson» មានន័យថាតន្ត្រីមានដើមកំណើតពីមៃខើល ចាកសាន់។ បើសិន «សេចក្តីសុចរិតរបស់ព្រះ» មានន័យបែបនេះ នោះឃ្លានេះកំពុងនិយាយថា ព្រះគឺជាប្រភពនៃសេចក្តីសុចរិតហើយ។ ក្នុងការកាត់ស្រាយនេះ ព្រះគឺជាប្រភពនៃសេចក្តីសុចរិតដែលទ្រង់ប្រទានដល់ពួកមនុស្សមានបាប។

តើការកាត់ស្រាយមួយណាត្រឹមត្រូវ? តើសេចក្តីសុចរិតជារបស់ព្រះ ឬតើវាអំណោយទានមកពីព្រះ? សេចក្តីថ្លែងទាំងពីរគឺពិតជាត្រឹមត្រូវ។ សេចក្តីសុចរិតជាលក្ខណៈសម្បត្តិសំខាន់មួយរបស់ព្រះ។ ការពិត ការសន្និដ្ឋាននៃការពិភាក្សារបស់ប៉ុលក្នុងគម្ពីររ៉ូម៣ គឺថា សូម្បីតែនៅពេលទ្រង់រាប់ពួកមនុស្សមានបាបជាសុចរិត ក៏ទ្រង់នៅតែរក្សាសេចក្តីសុចរិតរបស់ទ្រង់ដដែល! នៅក្នុងការរាប់ជាសុចរិត ព្រះ «សំដែងឲ្យឃើញសេចក្តីសុចរិតរបស់ព្រះនៅជាន់ឥឡូវនេះ ប្រយោជន៍ឲ្យទ្រង់បានសុចរិត ព្រមទាំងរាប់ពួកអ្នកមានសេចក្តីជំនឿ ជឿដល់ព្រះយេស៊ូវ ថាជាសុចរិតដែរ» (រ៉ូម ៣:២៦)។

លើសពីនេះទៅទៀត «សេចក្តីសុចរិតនៃព្រះ» ស្តីពីសេចក្តីពិតថា«ដោយព្រោះព្រះជាម្ចាស់សុចរិត ទ្រង់មិនអាចទទួលអ្នកណាដែលមិនសុចរិតនៅចំពោះព្រះអង្គទេ (គឺយើងចាំបាច់ត្រូវជាមនុស្សសុចរិតនៅចំពោះទ្រង់)»។[១៣] ហើយដែលទ្រង់ប្រទានដោយព្រះគុណជាអំណោយទានដល់គ្រប់គ្នាដែលជឿ។ ដូច្នេះ មានសេចក្តីសុចរិតមកពីព្រះសម្រាប់យើង ដែលជាសេចក្តីសុចរិតមិនត្រឹមតែរបស់ព្រះដែលទ្រង់សំដែងនោះទេ ប៉ុន្តែទ្រង់ក៏ប្រទានដល់យើងផងដែរ។ ជំលោះគឺមិនមែនថាតើ

ព្រះសុចរិតឬយ៉ាងណា នោះទេ (គ្រីស្ទបរិស័ទទាំងអស់យល់ព្រមថា ព្រះអង្គទ្រង់សុចរិត)ប៉ុន្តែថាតើព្រះអង្គអាចរាប់មនុស្សយើងជាសុចរិតចំពោះព្រះឬទេ។ ប៉ុលសរសេរក្នុងគម្ពីររ៉ូម ៣:២០ ថា «គ្មានមនុស្សណាបានរាប់ជាសុចរិតនៅចំពោះទ្រង់ទេ»។

ក្នុងខ. ២១ គាត់ប្រកាសដំណឹងល្អថា យើងអាចបានរាប់ជាសុចរិតនៅចំពោះព្រះ មិនមែនដោយសារសេចក្តីសុចរិតរបស់យើងផ្ទាល់នោះទេ តែដោយសារសេចក្តីសុចរិតដែលមកពីព្រះវិញ។ ខ. ២២ បញ្ជាក់ថាការកាត់ស្រាយនេះត្រឹមត្រូវដែលពិតជាសេចក្តីសុចរិតរបស់ព្រះ «បានមកដល់អស់អ្នកដែលជឿ»។ រ៉ូម ៥:១៧ ក៏បញ្ជាក់បន្ថែមទៀតថាការកាត់ស្រាយនេះត្រឹមត្រូវ ដែលនិយាយអំពីអស់អ្នកដែលទទួលបានព្រះគុណនិងសេចក្តីសុចរិតដ៏ជាអំណោយទានរបស់ព្រះ។ ដូច្នេះ សេចក្តីសុចរិតមិនគ្រាន់តែជាលក្ខណៈសម្បត្តិមួយដែលព្រះបង្ហាញនោះទេ ប៉ុន្តែវាក៏ជាអំណោយទានមួយដែលទ្រង់ប្រទានឲ្យផងដែរ។ យើងប្រើឃ្លារបស់លោក ចន ស្តុត John Stott ការរាប់ជាសុចរិតគឺជា «ផ្លូវសុចរិតនៃការធ្វើឲ្យមនុស្សទុច្ចរិតបានសុចរិត» របស់ព្រះ។[14]

បើសិនយើងបានរាប់ជាសុចរិតដោយផ្អែកលើអំណោយទានមួយ នោះប្រភពនៃការរាប់ជាសុចរិតរបស់យើងត្រូវតែជាព្រះគុណរបស់ព្រះ។ ពីព្រោះនោះជាអ្វីដែលព្រះគុណមានន័យ៖ អំណោយទានរបស់ព្រះដែលបានដោយទទេសម្រាប់ពួកមនុស្សមានបាបដែលមិនសមនឹងទទួល។ នេះគឺជាអំណោយនៃសេចក្តីសុចរិតដែលលោកប៉ុលកំពុងសរសេរនៅពេលគាត់សរសេរទៅកាន់ពួកក្រុងភីលីពថា គាត់ចង់«ហើយអោយគេបានឃើញខ្ញុំនៅក្នុងទ្រង់ដោយសេចក្តីសុចរិតដែលមកពីសេចក្តីជំនឿដល់ព្រះគ្រីស្ទមិនមែនដោយសេចក្តីសុចរិតរបស់ខ្លួនខ្ញុំដែលមកពីក្រិត្យវិន័យនោះទេគឺជាសេចក្តីសុចរិតដែលមកពីព្រះដោយសេចក្តីជំនឿវិញ» (ភីលីព ៣:៩ ប្រៀបធៀប ហេព្រើរ ១១:៧)

នេះក៏ជាអ្វីដែលបណ្ឌិត ម៉ាទីន លូធើរ ចង់មានន័យនៅពេលគាត់បាននិយាយអំពី «សេចក្តីសុចរិតពីខាងក្រៅ»។ ដោយសារគ្មានសេចក្តីសុចរិតនៅក្នុងយើង នោះយើងអាចបានរាប់ជាសុចរិតតាមរយៈសេចក្តីសុចរិតដែលមកពីខាងក្រៅយើងតែប៉ុណ្ណោះ។ សេចក្តីសុចរិតនេះគឺជាសេចក្តីសុចរិតរបស់ព្រះផ្ទាល់ ដែលទ្រង់ប្រទានដល់យើងតាមរយៈសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ។

## *មូលដ្ឋានគ្រឹះសម្រាប់ការរាប់ជាសុចរិត៖ ជីវិតដ៏ឥតខ្ចោះនិងការសុគតជាយញ្ញបូជារបស់ព្រះយេស៊ូវ*

តើឈរលើមូលដ្ឋានគ្រឹះអ្វីដែលព្រះប្រទានសេចក្តីសុចរិតដ៏ជាអំណោយទានរបស់ទ្រង់?ព្រះគម្ពីរបង្រៀនថា ព្រះ «ប្រោសឲ្យមនុស្សទមិលល្មើសបានសុចរិត» (រ៉ូម ៤:៥)។ ប៉ុន្តែបើសិនយើងទមិលល្មើស នោះតើទ្រង់អាចរាប់យើងជាសុចរិតនៅពេលយើងមិនសុចរិតបានយ៉ាងដូចម្តេច?ហើយតើទ្រង់អាចរាប់មនុស្សទមិលល្មើសជាសុចរិត ហើយមិនក្លាយជាព្រះដ៏ទមិលល្មើសផងដែរយ៉ាងដូចម្តេច? វាជាការខុសដែលព្រះដ៏សុចរិតមើលរំលងឬអត់ទោសអំពើបាប។ ដូច្នេះ បើសិនទ្រង់សព្វព្រះទ័យរាប់ពួកមនុស្សមានបាបជាសុចរិត នោះទ្រង់ត្រូវតែមានមូលដ្ឋានគ្រឹះតាមផ្លូវច្បាប់ដើម្បីធ្វើការនោះហើយ។ លោក ចន ស្តុត សរសេរថា

> ការរាប់ជាសុចរិតមិនមែនជាពាក្យន័យដូចជាមួយការលើកលែងទោស amnesty ដែលជាការអត់ទោសដែលមើលរំលងឬបំភ្លេចអំពើបាបហើយមិនកាត់ទោសវានោះឡើយ។ ទេ ការរាប់ជាសុចរិតគឺជាសកម្មភាពយុត្តិធម៌មួយជាសកម្មភាពយុត្តិធម៌ប្រកបដោយព្រះគុណ....នៅពេលព្រះរាប់ពួកមនុស្សមានបាបជាសុចរិត នោះទ្រង់មិនកំពុងប្រកាសថា មនុស្សអាក្រក់ទៅជាមនុស្សល្អ ឬកំពុងនិយាយថា ពួកគេលែងជាពួកមនុស្សមានបាបទៀតហើយ។ ទ្រង់កំពុងប្រកាសថា ពួកគេបានសុចរិតតាមផ្លូវច្បាប់ ពួកគេមិនមានអ្វីត្រូវសងច្បាប់ដែលពួកគេរំលងនោះឡើយ

ដោយព្រោះទ្រង់ផ្ទាល់នៅក្នុងព្រះរាជបុត្រារបស់ទ្រង់បានទទួលយកទោសសម្រាប់ការរំលងច្បាប់របស់ពួកគេរួចទៅហើយ។[១៥]

ដូច្នេះ តើព្រះរក្សាសេចក្ដីសុចរិតរបស់ទ្រង់ក្នុងពេលតែមួយដែលទ្រង់កំពុងរាប់មនុស្សទុច្ចរិតជាសុចរិតយ៉ាងដូចម្ដេច? ចម្លើយចំពោះបញ្ហានេះគឺថា ព្រះរាប់ពួកមនុស្សមានបាបជាសុចរិតដោយមានមូលដ្ឋានគ្រឹះនៃជីវិតដ៏ឥតខ្ចោះនិងការសុគតជាយញ្ញបូជារបស់ព្រះយេស៊ូវគ្រីស្ទ។ ព្រះយេស៊ូវបានរស់ក្នុងជិវិតដ៏ឥតខ្ចោះមួយគឺថា ទ្រង់បានរក្សាបានច្បាប់ដ៏ឥតខ្ចោះរបស់ព្រះទាំងអស់ ដោយមិនមានការរំលងសូម្បីតែបន្តិច។ នៅក្នុងចំណុចទី៧(ការប្រោសលោះនៃព្រះគ្រីស្ទ)នៃសេចក្ដីថ្លែងការណ៍អំពីគោលលិទ្ធិរបស់ក្រុមចម្រុះដំណឹងល្អមានការសរសេរថា «ទ្រង់បានស្ដាប់បង្គាប់យ៉ាងគ្រប់លក្ខណ៍ដល់ព្រះវរបិតាទ្រង់ដែលគង់នៅស្ថានសួគ៌» ។ សេចក្ដីថ្លែងនេះយោងទៅតាមបទគម្ពីរដែលនិយាយថា «ទ្រង់មិនបានធ្វើបាបសោះ» (១ពេត្រុស ២:២២)។ ព្រះយេស៊ូវបានរស់នៅក្នុងជីវិតសុចរិតដែលព្រះតម្រូវចង់បាន។

លើសពីនេះ នៅពេលយើងទទួលព្រះយេស៊ូវដោយសេចក្ដីជំនឿ នោះយើងបានទទួលសេចក្ដីសុចរិតរបស់ទ្រង់ដូចជាខ្លួនយើងបានរស់នៅក្នុងជីវិតសុចរិតដែលព្រះតម្រូវរួចហើយ។ យើងដកស្រង់ម្ដងទៀតចេញពីសេចក្ដីថ្លែងការណ៍អំពីសេចក្ដីជំនឿរបស់ក្រុមចម្រុះដំណឹងល្អ «ដោយសារការស្ដាប់បង្គាប់ដ៏គ្រប់លក្ខណ៍របស់ទ្រង់ព្រះយេស៊ូវបានបំពេញតាមការទាមទារដ៏សុចរិតរបស់ព្រះជំនួសយើងរាល់គ្នាដ្បិតដោយសារសេចក្ដីជំនឿតែម្យ៉ាងគត់ដែលព្រះរាប់អ្នកដែលបានទុកចិត្តលើព្រះគ្រីស្ទតែមួយអង្គគត់ដើម្បីឲ្យបានទទួលមកនៅជាមួយព្រះវិញថាជាការស្ដាប់បង្គាប់ដ៏គ្រប់លក្ខណ៍»។

តាមរយៈជីវិតដ៏ឥតខ្ចោះរបស់ទ្រង់ នៅពេលព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង ទ្រង់បានប្រទានយញ្ញបូជាឥតខ្ចោះសម្រាប់អំពើបាបរបស់យើង ការនេះក៏ជាផ្នែកនៃមូលដ្ឋានគ្រឹះសម្រាប់ការរាប់ជាសុចរិតរបស់យើងដែរ«តែដោយពឹងដល់ព្រះគុណទ្រង់ នោះបានរាប់ជាសុចរិតទទេដោយសារសេចក្ដីប្រោសលោះ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវដែលព្រះបានតាំងទ្រង់ទុកជាទីសន្ដោសប្រោស ដោយសារសេចក្ដីជំនឿដល់ព្រះលោហិតទ្រង់» (រ៉ូម ៣:២៤-២៥)

ប៉ុលសរសេរក្នុងរ៉ូម ៥:៩ ថា «ឥឡូវយើងបានរាប់ជាសុចរិតដោយសារព្រះលោហិតទ្រង់»។ ប្រសិនបើព្រះយេស៊ូវមិនជាប់ឆ្កាងទេ នោះគ្មានការរាប់ជាសុចរិតផងដែរ។ ដំណឹងល្អបង្ហាញថា ការរងទុក្ខសុគតរបស់ព្រះយេស៊ូវគ្រីស្ទគឺជាគ្រឹះនៃសេចក្ដីសង្គ្រោះពីព្រោះព្រះជាម្ចាស់បានរាប់យើងជាសុចរិតតាមរយៈការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ។ លោក ចន ស្តុត John Stott សរសេរថា៖

> ការងារសង្គ្រោះរបស់ព្រះត្រូវបានសម្រេចតាមរយៈការបង្ហូរព្រះលោហិតដែលជាយញ្ញបូជាជំនួសរបស់ព្រះគ្រីស្ទ... ការសុគតរបស់ព្រះយេស៊ូវគឺជាយញ្ញបូជាធួននឹងបាបដែលធ្វើឲ្យព្រះបានបង្វែរសេចក្ដីក្រោធរបស់ទ្រង់ចេញពីយើង ជាតម្លៃលោះដែលបានទិញលោះយើង ជាការផ្ដន្ទាទោសលើមនុស្សលើកលែងទោស ដែលមនុស្សមានទោសអាចបានរាប់ជាសុចរិតបាន ហើយព្រះដែលមិនមានបាបបានត្រឡប់ជាអំពើបាបជំនួសយើង។[១៦]

មុននេះយើងបានអានអំពីបទពិសោធន៍របស់លោក ដន ស្មាតតូ នៅពេលគាត់បានមើលឃើញគ្រោងឆ្អឹងតំណាងអំពើបាបពីខាងក្រោមអាវវែងដ៏មានអំណួតនៃសេចក្ដីសុចរិតខាងក្រៅរបស់គាត់។ នៅពេលលោក ស្មាតតូ បានត្រឡប់មកកុដិគ្រីស្ទបរិស័ទរបស់គាត់នៅយប់នោះ គាត់បានព្យាយាមរាប់ខ្លួនគាត់ជាសុចរិតនៅចំពោះព្រះ។ គាត់បានរក្សាការព្យាយាមប្រាប់ខ្លួនឯងថា គាត់ល្អគ្រប់គ្រាន់សម្រាប់ព្រះហើយ។ គាត់បានចេញដើរក្រោមពន្លឺព្រះច័ន្ទក្នុងចំការពោតដែលនៅជុំវិញ។ តែភ្លាមនោះពពកបានបាំងព្រះច័ន្ទ យប់ក៏ត្រឡប់ជាងងឹត។ នៅពេលលោក ស្មាតតូ បានជំពប់ជើងដួលនៅក្នុងភាពងងឹត ហើយបេះដូងរបស់គាត់លោតខ្លាំង នោះគាត់បានស្រែកទៅកាន់ព្រះថា «សូមប្រាប់ទូលបង្គំមកថា ទូលបង្គំកំពុងតែធ្វើការត្រឹមត្រូវ។ សូមប្រាប់ទូលបង្គំមកថា គ្រប់យ៉ាងដែលទូលបង្គំធ្វើផ្គាប់ព្រះហឫទ័យទ្រង់។ សូមមានបន្ទូលមកកាន់ទូលបង្គំឲ្យបានច្បាស់មក!»។

នៅពេលគាត់ស្ទើរតែអស់សង្ឃឹម លោក ស្មាតតូ បានឮសំឡេងបន្លឺសូរហ៊ឹមៗតិចៗចម្លែកមួយហើយគាត់បានដើរតម្រង់ទៅកាន់វា។ គាត់បានមកដល់ភាពងងឹតហើយដៃរបស់គាត់បានប៉ះឈើតាន់មួយដុំ។ វាគ្រាន់តែជាបង្គោលទូរស័ព្ទប៉ុណ្ណោះ។ ប៉ុន្តែនៅពេលគាត់មើលឡើងលើ ពពកបានចាប់ផ្ដើមរសាត់ហើយគាត់អាចមើលឃើញឈើទទឹងដែលបានធ្វើឲ្យលើកខ្សែភ្លើងទូរស័ព្ទឡើង។ មានរូបស្រមោលខ្មៅប្រទល់នឹងពន្លឺព្រះច័ន្ទ គឺជារូបឈើឆ្កាងមួយ។ លោក ដន ស្មាតតូ បានកំពុងឈរនៅឯជើងឈើឆ្កាង មើលទៅកាន់ព្រះយេស៊ូវសម្រាប់សេចក្ដីសង្គ្រោះ។ នេះគឺជាអ្វីដែលលោក ស្មាតតូ បានសរសេរអំពីការដែលគាត់បានជួបជាមួយព្រះយេស៊ូវនិងឈើឆ្កាង៖

> ឥឡូវនេះខ្ញុំបានដឹង ខ្ញុំពិតជាបានដឹងហើយថា ព្រះគ្រីស្ទបានសុគតជំនួសខ្ញុំ។ នេះពាក់ព័ន្ធនឹងការបើកសំដែងកាន់តែច្បាស់ថា ខ្ញុំជាមនុស្សមានបាបម្នាក់ ថាខ្ញុំមិនមែនជាមនុស្សល្អដូចដែលខ្ញុំបានគិតនោះទេ។ ភ្លាមៗនោះខ្ញុំបានអោបបង្គោលទូរស័ព្ទហើយចាប់ផ្ដើមយំ។ ខ្ញុំពិតជាបានអោបឈើនោះអស់ជិតមួយម៉ោង។ ខ្ញុំអាចគិតក្នុងមនោគតិថា ព្រះយេស៊ូវត្រូវគេវាយភ្ជាប់នឹងបង្គោលនេះ លោហិតហូរស្រក់ពីរបួសរបស់ទ្រង់។ ខ្ញុំបានមានអារម្មណ៍ថា លោហិតកំពុងហូរស្រក់មកលើខ្ញុំ សំអាតខ្ញុំពីអំពើបាបនិងភាពមិនសមនឹងទទួលសេចក្ដីសង្គ្រោះពីទ្រង់។[១៧]

អ្វីដែលលោក ដន ស្មាតតូ បានទទួលក្នុងបទពិសោធន៍នេះគឺពិតជាអ្វីដែលអ្នកលន់តួប្រែចិត្តទទួលបាននៅឯជើងឈើឆ្កាង៖ យញ្ញបូជាលោហិតលាងសំអាតដែលធួននឹងអំពើបាបហើយរាប់ពួកមនុស្សមានបាបជាសុចរិតនៅចំពោះព្រះ។

## *សេចក្ដីសុចរិតនៃការរាប់ជាសុចរិត៖ ការផ្ទេរឲ្យបីដង*

នៅពេលព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង គេបានចាត់ទុកទ្រង់ជាឧក្រិដ្ឋជនដែលបានកាត់ទោសហើយ។ ពួករ៉ូមម៉ាំងបម្រុងទុកការឆ្កាងសម្រាប់អ្នកអន់បំផុត សម្រាប់ជនក្បត់ជាតិ ឃាតករ និងមនុស្សដែលគួរឲ្យស្អប់ខ្ពើមដទៃទៀត។ ព្រះយេស៊ូវមិនមែនជាជនក្បត់ជាតិ ឬឃាតករ ការពិតដូចជាយើងបានឃើញថា ទ្រង់មិនដែលធ្វើបាបសោះ (សូមមើលហេព្រើរ ៤:១៥)។ ប៉ុន្តែព្រះបានអនុញ្ញាតឲ្យគេឆ្កាងទ្រង់ដើម្បីដោះអំពើបាបរបស់យើងចេញ។ ព្រះបានផ្ទេរអំពើបាបរបស់យើងទៅលើព្រះគ្រីស្ទ។ ផ្ទេរទោសគឺត្រូវប្រគល់អ្វីមួយឲ្យអ្នកណាម្នាក់ទទួលខុសត្រូវ ដែលជារបៀបដែលយើងត្រឡប់ជាពួកមនុស្សមានបាបមុនដំបូង៖ អំពើបាបរបស់អ័ដាមត្រូវបានចោទប្រកាន់មកលើយើង (សូមមើលរ៉ូម ៥:១២-១៩)។ តាមរយៈការផ្ទេរទោសរបស់អ័ដាម នោះព្រះចាត់ទុកយើងជាពួកមនុស្សមានបាប។

គួរឲ្យសប្បាយរីករាយដែលមានការផ្ទេរទោសទីពីរ គឺការផ្ទេរអំពើបាបរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ។ ព្រះយេស៊ូវគឺសុចរិតឥតខ្ចោះ តែទ្រង់បានសុគតក្នុងសេចក្ដីស្លាប់របស់មនុស្សមានបាប។ តើព្រះអាចអនុញ្ញាតឲ្យរឿងបែបនេះកើតឡើងយ៉ាងម៉េចទៅ? ចំលើយគឺ ដើម្បីផ្ទេរទោសរបស់យើងទៅលើទ្រង់។ ព្រះបានដោះអំពើបាបរបស់យើងចេញ ហើយប្រគល់វាឲ្យព្រះគ្រីស្ទទទួលខុសត្រូវ ដូចដែលទ្រង់បានសន្យាតាមរយៈអេសាយជាអ្នកបម្រើទ្រង់ថា «អ្នកដ៏សុចរិត គឺជាអ្នកបម្រើរបស់អញ ទ្រង់នឹងធ្វើឲ្យមនុស្សជាច្រើនបានសុចរិត ដោយគេស្គាល់ដល់ទ្រង់ ហើយទ្រង់នឹងទទួលរងទោសចំពោះអំពើទុច្ចរិតរបស់គេ» (អេសាយ ៥៣:១១)។ នៅពេលអំពើបាបរបស់យើងត្រូវបានផ្ទេរលើព្រះគ្រីស្ទក្នុងរបៀបនេះ នោះទ្រង់ត្រូវបានកាត់ទោសដល់សុគត មិនមែនដោយសារអំពើបាបរបស់ទ្រង់ផ្ទាល់នោះទេ ប៉ុន្តែដោយសារអំពើបាបរបស់យើងវិញ។ ព្រះចាត់ទុកព្រះយេស៊ូវជាទុច្ចរិតនៅលើឈើឆ្កាង។ ដោយមើលឃើញថាទ្រង់កំពុងទទួលទោសនៃអំពើបាបរបស់យើង នោះព្រះបានកាត់ទោសអំពើបាបរបស់យើងនៅក្នុងសាច់ឈាមរបស់ទ្រង់ (សូមមើលរ៉ូម ៨:៣)។ ដូចជាបទគម្ពីរនិយាយថា «ព្រះបានធ្វើឲ្យទ្រង់ដែលមិនស្គាល់បាបនោះ ត្រឡប់ជាតួបាបជំនួសយើង»(២កូរិនថូស ៥:២១)។ បទគម្ពីរនិយាយម្តងទៀតថា «ព្រះគ្រីស្ទបានសុគតសម្រាប់អំពើបាបម្ដងជាសម្រេច គឺមនុស្សសុចរិតសម្រាប់មនុស្សទុច្ចរិត» (១ពេត្រុស ៣:១៨)។

ប៉ុន្តែការសុគតរបស់ព្រះគ្រីស្ទមិនមែនជាចុងបញ្ចប់របស់រឿងនោះទេ។ បទគម្ពីរក៏និយាយអំពីការប្រទាន(ទម្លាក់)ឲ្យទីបីផងដែរ «ដ្បិតឯព្រះអង្គដែលមិនបានស្គាល់បាបសោះ នោះព្រះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នា ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះ ដោយនូវព្រះអង្គនោះឯង» (២កូរិនថូស ៥:២១)។ បើសិនយើងត្រូវតែបានរាប់ជាសុចរិត នោះវាមិនគ្រប់គ្រាន់ដែលទម្លាក់អំពើបាបរបស់យើងទៅលើព្រះគ្រីស្ទនោះទេ ប៉ុន្តែសេចក្តីសុចរិតរបស់ទ្រង់ក៏ត្រូវបានចែក(ផ្ទេរ)មកឲ្យយើងផងដែរ។ មានតែបន្ទាប់ពីនោះទេដែលយើងអាចបានរាប់ជាសុចរិត។ នេះគឺពិតជាអ្វីដែលព្រះបានធ្វើ។ ដូច្នេះ ព្រះបានប្រទានសេចក្តីសុចរិតមកដល់យើង ហើយទ្រង់បានចែក(ផ្ទេរ)សេចក្តីសុចរិតនេះដល់យើងដោយផ្អែកលើជីវិតដ៏ឥតខ្ចោះនិងការសុគតជាយញ្ញបូជារបស់ព្រះគ្រីស្ទ។

ទីនេះវាមានប្រយោជន៍សម្រាប់យើងក្នុងការបែងចែកសេចក្តីសុចរិតសកម្មនិងសេចក្តីសុចរិតអកម្មឲ្យខុសពីគ្នា។ ព្រះយេស៊ូវបានសំដែងសេចក្តីសុចរិតសកម្មរបស់ទ្រង់តាមរយៈការបំពេញសម្រេចការប្រព្រឹត្តតាមក្រឹត្យវិន័យ ហើយទ្រង់បានសំដែងសេចក្តីសុចរិតអកម្មរបស់ទ្រង់តាមរយៈសងថ្លៃទណ្ឌកម្មសម្រាប់អំពើបាបរបស់យើង។ព្រះគ្រីស្ទបានស្តាប់បង្គាប់តាមក្រឹត្យវិន័យរបស់ព្រះជំនួសឲ្យយើង (សេចក្តីសុចរិតសកម្ម) ហើយទទួលរងទណ្ឌកម្មសម្រាប់ការមិនស្តាប់បង្គាប់របស់យើង (សេចក្តីសុចរិតអកម្ម)។

សេចក្តីសុចរិតសកម្មនិងអកម្មគឺជាចំនុចពីរខុសគ្នារបស់សេចក្តីសុចរិតពេញលេញរបស់ព្រះយេស៊ូវគ្រីស្ទ ហើយការរាប់ជាសុចរិតតម្រូវឲ្យមានសេចក្តីសុចរិតទាំងពីរនេះ។ ដើម្បីយើងបានត្រឡប់ជា «គ្មានទោស» យើងចាំបាច់ទទួលយកសេចក្តីសុចរិតសកម្មរបស់ព្រះគ្រីស្ទតាមរយៈការសុគតជួននឹងបាបរបស់ទ្រង់។ តែដើម្បីឲ្យព្រះចាត់ទុកយើងជាសុចរិត នោះយើងក៏ត្រូវការព្រះប្រទានសេចក្តីសុចរិតអកម្មរបស់ព្រះគ្រីស្ទមកដល់យើងផងដែរ។ ដូច្នេះ មិនត្រឹមតែការសុគតជួននឹងបាបរបស់ទ្រង់ដែលសង្គ្រោះយើងនោះទេ ប៉ុន្តែជីវិតស្តាប់បង្គាប់របស់ទ្រង់ក៏សង្គ្រោះយើងផងដែរ។

ការប្រទាន(ផ្ទេរ)សេចក្តីសុចរិតនេះមិនមែនជា «រឿងប្រឌិត» ដូចអ្នកខ្លះបានចោទប្រកាន់នោះទេ ប៉ុន្តែជាសេចក្តីពិតតាមផ្លូវច្បាប់ដែលផ្អែកលើទំនាក់ទំនងរបស់យើងជាមួយព្រះយេស៊ូវគ្រីស្ទ។ ការរាប់ជាសុចរិតហូរចេញពីការរួបរួមរបស់យើងជាមួយព្រះគ្រីស្ទដូចជាគុណតម្លៃផ្សេងៗទៀតរបស់សេចក្តីសង្គ្រោះដែរ។ ព្រះយេស៊ូវគឺជាសេចក្តីសុចរិតរបស់យើង (១កូរិនថូស ១:៣០) ដូច្នេះ ដើម្បីឲ្យយើងបានរាប់ជាសុចរិត មានតែការចូលរួមនៅក្នុងទ្រង់ប៉ុណ្ណោះ។ ដូចជាបណ្ឌិត ចន កាលវិន ពន្យល់ថា «ព្រះគ្រីស្ទដែលព្រះបានធ្វើឲ្យទ្រង់ត្រឡប់ជារបស់យើង ធ្វើឲ្យយើងត្រឡប់ជាអ្នកមានចំណែកជាមួយទ្រង់ក្នុងអំណោយទានដែលទ្រង់បានប្រទានឲ្យ។ ដូច្នេះ យើងមិនគិតថាទ្រង់គង់នៅខាងក្រៅខ្លួនយើងហើយនៅឆ្ងាយពីយើងដើម្បីឲ្យសេចក្តីសុចរិតរបស់ទ្រង់បានចែកមកដល់យើងនោះទេ។ ប៉ុន្តែជាសង្ខេប ដោយសារយើងដាក់ព្រះគ្រីស្ទលើខ្លួនយើងនិងផ្សាំទៅក្នុងរូបកាយរបស់ទ្រង់ ហើយដោយសារទ្រង់បានយាងចុះមកធ្វើឲ្យយើងត្រឡប់ជាតែមួយជាមួយទ្រង់។ ដោយហេតុផលនេះ យើងមានអំណរដែលយើងមានសេចក្តីសុចរិតជាមួយទ្រង់»។

ដូច្នេះ សេចក្តីសង្គ្រោះពឹងផ្អែកលើការផ្ទេរឲ្យបីដង៖ ទីមួយ តាមរយៈការធ្លាក់ចុះរបស់អ័ដាម អំពើបាបត្រូវធ្លាក់លើមនុស្សជាតិ។ ទីពីរ អំពើបាបរបស់អ្នកជឿ ម្នាក់ត្រូវផ្ទេរទៅលើព្រះគ្រីស្ទនៅពេលប្រែចិត្តជឿ។ ទីបី សេចក្តីសុចរិតរបស់ព្រះគ្រីស្ទត្រូវប្រទានដល់មនុស្សមានបាបដែលជឿព្រះគ្រីស្ទតាមរយៈសេចក្តីជំនឿ។ ប៉ុលសង្ខេបគំនិតនេះក្នុងរ៉ូម ៥ ថា៖

> ដូច្នេះដែលមនុស្សទាំងអស់ត្រូវទោសដោយព្រោះអំពើរំលងតែ១នោះមនុស្សទាំងអស់ក៏បានរាប់ជាសុចរិតឱ្យបានជីវិតវិញដោយសារអំពើសុចរិតតែ១បែបដូច្នោះដែរដ្បិតដូចជាមនុស្សជាច្រើនបានត្រឡប់ជាមានបាបដោយសារមនុស្សតែម្នាក់មិនបានស្តាប់បង្គាប់ជាយ៉ាងណានោះមនុស្សជាច្រើនក៏បានត្រឡប់ជាសុចរិតដោយសារម្នាក់បានស្តាប់បង្គាប់វិញយ៉ាងនោះដែរ។ (រ៉ូម ៥:១៨-១៩)

ការប្រទានសេចក្តីសុចរិតតាមរយៈព្រះអង្គរាប់យើងជាសុចរិតស្តារឡើងវិញនូវសេចក្តីសុចរិតដែលមនុស្សជាតិបានបាត់បង់ដោយសារអំពើបាបដំបូង។ អស្ចារ្យណាស់ដែលសេចក្តីសុចរិតនេះត្រូវបានស្តារឡើងវិញដោយឥតមានការធ្វើអំពើ

អយុត្តិធម៌ណាមួយចំពោះលក្ខណៈសម្បត្តិរបស់ព្រះនោះទេ។ ព្រះបានដោះស្រាយយ៉ាងយុត្តិធម៌ជាមួយអំពើបាបរបស់យើងដោយការដាក់ទណ្ឌកម្មវាលើអង្គបុគ្គលរបស់ព្រះគ្រីស្ទដែលត្រូវគេឆ្កាង។ ទ្រង់ក៏បានដោះស្រាយយ៉ាងយុត្តិធម៌ផងដែរដោយការរាប់យើងជាសុចរិតនៅក្នុងព្រះគ្រីស្ទ។ ព្រះបានសម្រេចបាននូវការងាររាប់ជាសុចរិតនេះតាមរយៈឈើឆ្កាងដើម្បី «នឹងសំដែងឱ្យឃើញសេចក្តីសុចរិតរបស់ព្រះនៅជាន់ឥឡូវនេះប្រយោជន៍ឱ្យទ្រង់បានសុចរិតព្រមទាំងរាប់ពួកអ្នកដែលមានសេចក្តីជំនឿជឿដល់ព្រះយេស៊ូវថាជាសុចរិតដែរ»។ (រ៉ូម ៣:២៦)

តាមរយៈការដែលព្រះរាប់យើងជាសុចរិត ព្រះបង្ហាញយុត្តិធម៌របស់ទ្រង់ដោយការដោះស្រាយបញ្ហារបស់ពួកមនុស្សមានបាបដោយយុត្តិធម៌និងសេចក្តីមេត្តាករុណាតាមរយៈឈើឆ្កាង។ ដំណោះស្រាយ(ដោយការជួញដូរ)បានកើតឡើង៖ អំពើបាបរបស់យើងត្រូវបានទម្លាក់លើព្រះគ្រីស្ទ ហើយទ្រង់ត្រូវជាប់មានទោស សេចក្តីសុចរិតរបស់ទ្រង់ត្រូវបានប្រទានដល់យើង ហើយយើងបានរាប់ជាសុចរិត។

## *ឧបករណ៍របស់ការរាប់ជាសុចរិត៖ សេចក្តីជំនឿក្នុងព្រះគ្រីស្ទ*

មុននេះយើងបានផ្តល់អត្ថន័យលើការរាប់ជាសុចរិត។ ឥឡូវនេះយើងអាចពង្រីកការយល់ដឹងរបស់យើងបន្តិចតាមរយៈការពិចារណាខាងទេវសាស្ត្របន្ថែមទៀត៖

> ការរាប់ជាសុចរិតមានន័យជាការផ្លាស់ប្តូរជាអចិន្ត្រៃយ៍ក្នុងទំនាក់ទំនងតាមផ្លូវច្បាប់ជាមួយនឹងព្រះដែលព្រះបានលើកលែងយើងឲ្យរួចពីការចោទប្រកាន់ទោស ហើយដែលព្រះអត់ទោសរាល់អំពើបាបរបស់យើងដោយផ្អែកលើការងារចប់សព្វគ្រប់របស់ព្រះយេស៊ូវគ្រីស្ទ។ ក្រៅពីព្រះគ្រីស្ទ នោះទំនាក់ទំនងតាមផ្លូវច្បាប់របស់យើងជាមួយនឹងព្រះគឺជាការផ្តន្ទាទោសមួយ គឺយើងជាប់មានទោសដោយសារអំពើបាបរបស់យើង។ នៅពេលយើងបានរាប់ជាសុចរិត នោះទំនាក់ទំនងតាមផ្លូវច្បាប់របស់យើងជាមួយនឹងព្រះត្រូវបានផ្លាស់ប្តូរពីការផ្តន្ទាទោសទៅការលើកលែងទោសវិញ។[១៩]

សៀវភៅអំពីគោលជំនឿសំខាន់ៗតាមរបៀបសំនួរចម្លើយខ្នាតតូចរបស់វេសមីនស្ទ័រ The Westminster Shorter Catechism ផ្តល់និយមន័យខ្លីនិងកាន់តែច្បាស់លាស់មួយថា «ការរាប់ជាសុចរិតគឺជាសកម្មភាពព្រះបានសម្រេចដោយសារព្រះគុណដែលយើងទទួលដោយទទេ ដែលទ្រង់អត់ទោសរាល់អំពើបាបរបស់យើង ហើយរាប់យើងជាសុចរិតនៅចំពោះទ្រង់ដោយទ្រង់បានប្រទានសេចក្តីសុចរិតរបស់ព្រះគ្រីស្ទមកដល់យើង ហើយយើងទទួលបានសេចក្តីសុចរិតនោះតាមរយៈសេចក្តីជំនឿតែមួយគត់» (A. 33)។

ឃ្លាចុងក្រោយនៅក្នុងនិយមន័យពីសៀវភៅអំពីគោលជំនឿសំខាន់ៗតាមរបៀបសំនួរចម្លើយគឺសំខាន់ ពីព្រោះវាបញ្ជាក់ប្រាប់ថាសេចក្តីជំនឿជាផ្លូវតែមួយគត់ក្នុងការទទួលបានការរាប់ជាសុចរិត។ រ៉ូម ៣ បានលើកឡើងអំពីសេចក្តីជំនឿយ៉ាងហោចណាស់ចំនួនប្រាំមួយដង៖

«គឺជាសេចក្តីសុចរិតរបស់ព្រះ ដែលបានដោយសារសេចក្តីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទ ក៏សម្រាប់គ្រប់អស់អ្នកណាដែលជឿផង» (រ៉ូម ៣:២២)«ដែលព្រះបានតាំងទ្រង់ទុកជាទីសន្តោសប្រោស ដោយសារសេចក្តីជំនឿដល់ព្រះលោហិតទ្រង់» (រ៉ូម ៣:២៥) នៅក្នុងខ.២៦ ទ្រង់គឺជាព្រះដែល «រាប់ពួកអ្នកដែលមានសេចក្តីជំនឿជឿដល់ព្រះយេស៊ូវថាជាសុចរិត»។

អំនួតត្រូវដកចេញពីគោលការណ៍សេចក្តីជំនឿក្នុងខ. ២៧ «ដ្បិតយើងខ្ញុំអាងថា មនុស្សបានរាប់ជាសុចរិត ដោយសារសេចក្តីជំនឿ គឺមិនមែនដោយការប្រព្រឹត្តតាមក្រឹត្យវិន័យទេ» (រ៉ូម ៣:២៨ សូមប្រៀបធៀប ៥:១)។ អ្វីដែលបទគម្ពីរនេះសង្កត់លើម្តងហើយម្តងទៀតគឺសំខាន់ចំពោះដំណឹងល្អ៖ យើងបានរាប់ជាសុចរិតដោយសារសេចក្តីជំនឿ។ ពេលខ្លះមនុស្សឆ្ងល់អំពីអ្វីដែលពួកគេត្រូវតែធ្វើដើម្បីរាប់ខ្លួនគេជាសុចរិតនៅចំពោះព្រះ។ ចម្លើយគឺថា គ្មានអ្វីដែលយើងអាចធ្វើទេ លើក

លែងតែជឿប៉ុណ្ណោះ។ មានកន្លែងនេះដែលជំនឿគ្រីស្ទបរិស័ទខុសពីសាសនាដទៃៗទៀត ខុសពីការប៉ុនប៉ងរបស់មនុស្ស ដើម្បីទទួលបានសេចក្តីសុចរិត។ សេចក្តីពិតនេះពិបាកសម្រាប់ពួកអ្នកមិនជឿយល់ពួកគេរិះគិតសួរថា តើមិនមានអ្វីមួយដែលយើងអាចធ្វើដើម្បីធ្វើឲ្យខ្លួនយើងល្អគ្រប់គ្រាន់ចំពោះព្រះទេឬ?

ថ្មចារិកនៅលើផ្នូរខ្មោចនៅសតវត្សទីមួយផ្តល់ឲ្យឧទាហរណ៍មួយអំពីការមានទំនុកចិត្តខុសរបស់មនុស្សលើការប្រព្រឹត្តដើម្បីរាប់ខ្លួនឯងជាសុចរិត។ ថ្មចារិកសរសេរថា

> រីជីណា Regina ដេកនៅទីនេះ...នាងនឹងរស់ឡើងវិញត្រឡប់ទៅពន្លឺម្តងទៀត ពីព្រោះនាងអាចសង្ឃឹមថា នាងនឹងរស់ឡើងមកជីវិតដែលព្រះបានសន្យាសម្រាប់អ្នកសុចរិតដោយព្រោះនាងបានសមនឹងរស់នៅក្នុងទឹកដីបរិសុទ្ធ។ ជីវិតសុចរិតរបស់អ្នក សេចក្តីស្រលាញ់របស់អ្នកចំពោះមនុស្សរបស់អ្នក ការគោរពតាមក្រឹត្យវិន័យរបស់អ្នក ការប្តេជ្ញារបស់អ្នកចំពោះអាពាហ៍ពិពាហ៍របស់អ្នក ធានាថា អ្នកនឹងទៅរស់នៅទឹកដីបរិសុទ្ធ។ ការប្រព្រឹត្តទាំងនេះធានាដល់សេចក្តីសង្ឃឹមរបស់អ្នកទៅអនាគត។[២០]

ថ្មចារិកនៅលើផ្នូររបស់រីជីណាគឺធម្មតាជាពិសេសសម្រាប់មនុស្សមានកាន់តាមសាសនា។ វាសន្មត់ថា ការប្រព្រឹត្តសុចរិតគឺជាការធានាតែមួយដែលមនុស្សម្នាក់នឹងទៅស្ថានសួគ៌។ តែអ្នកណាដែលសង្ឃឹមថា ព្រះជាម្ចាស់នឹងទទួលគេដោយការប្រព្រឹត្តតាមក្រឹត្យវិន័យ អ្នកនោះបានធ្លាក់ទៅក្នុងក្រិត្យវិន័យនិយមដែលបំផ្លាញព្រលឹង។បណ្ឌិត ម៉ាទីន លូធើរ បានលើកអំពីចំនុចនេះថា ការគិតថាយើងអាចទទួលព្រះគុណរបស់ព្រះដោយការប្រព្រឹត្តរបស់យើងគឺពិតជារបៀបមួយដែល «យើងព្យាយាមផ្គាប់ដល់ព្រះហឫទ័យព្រះតាមរយៈបាបរបស់យើង»។

នៅពេលព្រះយេស៊ូវបានពន្យល់របៀបពិតនៃការរាប់ជាសុចរិតទៅកាន់ពួកសិស្សរបស់ទ្រង់ ទ្រង់បានប្រយ័ត្នប្រយែងក្នុងធ្វើឲ្យខុសគ្នារវាងសេចក្តីជំនឿនិងការស្តាប់បង្គាប់។ ពួកសិស្សបានសួរទ្រង់ថា «ដែលនឹងធ្វើការរបស់ព្រះ តើត្រូវធ្វើដូចម្តេចខ្លះ?» ព្រះយេស៊ូវមានបន្ទូលឆ្លើយថា «ឯការរបស់ព្រះ គឺឲ្យអ្នករាល់គ្នាបានជឿដល់អ្នកដែលព្រះបានចាត់ឲ្យមក» (យ៉ូហាន ៦:២៨-២៩)។ ឆ្មាំគុកក្នុងក្រុងភីលីពបានសួរសាវ័កប៉ុលនូវសំនួរដូចគ្នា «តើឲ្យខ្ញុំត្រូវធ្វើដូចម្តេចឲ្យបានសង្គ្រោះផង?» ប៉ុលបានឆ្លើយចម្លើយដូចដែលព្រះយេស៊ូវបានឆ្លើយថា «ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅ នោះនឹងបានសង្គ្រោះហើយ» (កិច្ចការ ១៦:៣០-៣១)។ និយាយក្នុងរបៀបផ្សេង គ្មានអ្វីដែលយើងអាចធ្វើដើម្បីរាប់ខ្លួនយើងជាសុចរិតនៅចំពោះព្រះបាននោះឡើយ។ សេចក្តីសុចរិតតែមួយដែលទ្រង់ទទួលបានលេចមក «ក្រៅពីក្រឹត្យវិន័យ» (រ៉ូម ៣:២១)។

ដូច្នេះ ការតែមួយដែលយើងអាចធ្វើដើម្បីបានសេចក្តីសង្គ្រោះគឺ ការដាក់សេចក្តីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ។ បើសិនយើងទុកចិត្តលើទ្រង់និងការងាររាប់ជាសុចរិតរបស់ទ្រង់នៅលើឈើឆ្កាង នោះ ទ្រង់នឹងរាប់យើងជាសុចរិត។ ព្រះទទួលយកយើងមិនដោយសារការប្រព្រឹត្តតាមក្រឹត្យវិន័យរបស់ទ្រង់នោះទេ ប៉ុន្តែដោយការទុកចិត្តលើមនុស្សម្នាក់ដែលបានប្រព្រឹត្តតាមគ្រប់ទាំងក្រឹត្យវិន័យយ៉ាងឥតខ្ចោះ គឺព្រះយេស៊ូវគ្រីស្ទ។ ការប្រែចិត្តជឿរបស់បណ្ឌិត ម៉ាទីន លូធើរ បានបង្ហាញយ៉ាងច្បាស់លាស់អំពីភាពខុសគ្នារវាងការបានរាប់ជាសុចរិតដោយការប្រព្រឹត្តនិងការបានរាប់ជាសុចរិតដោយការជឿ។ នៅពេលគាត់នៅជាសង្ឃម្នាក់នៅឡើយ គាត់បានចាប់អារម្មណ៍យ៉ាងខ្លាំងលើខគម្ពីរមួយក្នុងកណ្ឌហាបាគុក ដែលសាវ័កប៉ុលបានដកស្រង់នៅក្នុងសំបុត្ររបស់គាត់ទៅកាន់ពួកកាឡាទី «មនុស្សសុចរិតនឹងរស់ដោយអាងសេចក្តីជំនឿ» (កាឡាទី ៣:១១ ប្រៀបធៀប ហាបាគុក ២:៤)។

លូធើរបានអានខគម្ពីរមួយនេះនៅក្នុងកុដិគ្រីស្ទបរិស័ទនៅឯអើហ្វឺត Erfurt បើទោះដំបូងគាត់មិនច្បាស់ថាខគម្ពីរនេះមានន័យយ៉ាងម៉េច។ បន្ទាប់មកទៀត គាត់បានមានជំងឺនិងការធ្លាក់ទឹកចិត្តធ្ងន់ធ្ងររហូតដល់គាត់បានគិតក្នុងមនោគតិថាគាត់បាននៅក្រោមសេចក្តីក្រោធរបស់ព្រះ។ ដោយដេកលើគ្រែក្នុងប្រទេសអ៊ីតាលី ហើយភ័យខ្លាចថាគាត់ត្រូវស្លាប់ក្នុង

ពេលឆាប់ៗ នោះលូធើរបានសូត្រខគម្ពីរនេះដដែលៗថា «មនុស្សសុចរិតនឹងរស់ដោយអាងសេចក្តីជំនឿ។ មនុស្សសុចរិតនឹងរស់ដោយអាងសេចក្តីជំនឿ»។

លូធើរបានជាសះស្បើយ ហើយមិនយូរប៉ុន្មានគាត់បានទៅរ៉ូម ជាកន្លែងដែលគាត់បានទៅពួកជំនុំ St. John Lateran ។ សម្តេចប៉ាបបានសន្យានឹងផ្តល់គ្រឿងលោះបាបដែលអត់ទោសអំពើបាបរបស់អ្នកធ្វើធម្មយាត្រាណាដែលបានឡើងកាំជណ្តើររបស់ព្រះវិហារ ដែលពួកគេអះអាងថា បានមកពីសាលាក្តីរបស់ប៉ុនទាស ពីឡាត់។ ដោយជឿថាកាំជណ្តើរប្រឡាក់ដោយលោហិតរបស់ព្រះគ្រីស្ទ នោះអ្នកធ្វើធម្មយាត្រាបានឡើងជណ្តើរដោយជង្គង់របស់ពួកគេ ហើយឈប់ជារឿយៗដើម្បីអធិស្ឋាននិងថើបកាំជណ្តើរបរិសុទ្ធនោះ។

រឿងរបស់លូធើរបន្តជាពាក្យរបស់កូនប្រុសរបស់គាត់ថា (ពីឯកសារសរសេរដៃដែលបានរក្សាទុកក្នុងបណ្ណាល័យរបស់ Rudolstadt) «នៅពេលគាត់អធិស្ឋានដដែលៗនៅលើកាំជណ្តើរ ភ្លាមនោះគាត់បាននឹកឃើញពាក្យរបស់ហោរាហាបាគុកថា 'មនុស្សសុចរិតនឹងរស់ដោយអាងសេចក្តីជំនឿ'។ គាត់បានបញ្ឈប់សេចក្តីអធិស្ឋានរបស់គាត់ ត្រឡប់ទៅ Wittenberg វិញ ហើយបានយកខគម្ពីរនេះជាគ្រឹះសំខាន់សម្រាប់គោលលទ្ធិទាំងអស់របស់គាត់»។ លូធើរលែងជឿថា មានអ្វីដែលគាត់អាចធ្វើដើម្បីឲ្យព្រះអង្គគាប់ព្រះហឫទ័យនឹងគាត់ ហើយគាត់បានចាប់ផ្តើមរស់នៅដោយសេចក្តីជំនឿលើព្រះរាជបុត្រានៃព្រះវិញ។ បន្ទាប់មកគាត់បាននិយាយថា៖

> ពីមុនពាក្យទាំងនោះបានចូលគំនិតរបស់ខ្ញុំខ្ញុំបានស្អប់និងខឹងចំពោះព្រះ...ប៉ុន្តែនៅពេលខ្ញុំបានយល់ពាក្យទាំងនោះដោយព្រះវិញ្ញាណនៃព្រះ “មនុស្សសុចរិតនឹងរស់ដោយអាងសេចក្តីជំនឿ!” “មនុស្សសុចរិតនឹងរស់ដោយអាងសេចក្តីជំនឿ!” បន្ទាប់មកខ្ញុំបានមានអារម្មណ៍ថា ខ្ញុំបានកើតជាថ្មីដូចជាមនុស្សថ្មីម្នាក់ គឺខ្ញុំបានចូលតាមទ្វារបើកទៅក្នុងស្ថានសួគ៌នៃព្រះ។[២២]

នៅពេលព្រះគម្ពីរនិយាយថា យើងបានរាប់ជាសុចរិត «ដោយសារសេចក្តីជំនឿ» ឬ «តាមរយៈសេចក្តីជំនឿ» គឺវាអះអាងថា សេចក្តីជំនឿគឺជាឧបករណ៍របស់ការរាប់ជាសុចរិតរបស់យើង ជាបំពង់ដែលបង្ហូរសេចក្តីសុចរិតរបស់ព្រះយេស៊ូវគ្រីស្ទមកដល់យើង។ លោក J. I. Packer បានសរសេរអំពីសេចក្តីជំនឿថាជា «ដៃលាទទេដែលទទួលបានសេចក្តីសុចរិតដោយការទទួលយកព្រះគ្រីស្ទ»។[២៣] លោក រីល J. C. Ryle បានផ្តល់អត្ថន័យលើសេចក្តីជំនឿស្រដៀងនេះថាជា

> ការលូកចាប់ព្រះហស្តរបស់ព្រះអង្គសង្គ្រោះ ការផ្អែកលើដៃរបស់ប្តី និងការទទួលថ្នាំពេទ្យរបស់គ្រូពេទ្យ។ (សេចក្តីជំនឿ) មិននាំអ្វីទៅឲ្យព្រះគ្រីស្ទនោះទេ ប៉ុន្តែនាំព្រលឹងមនុស្សមានបាបទៅឲ្យព្រះគ្រីស្ទវិញ។ សេចក្តីជំនឿមិនឲ្យអ្វី មិនជួយជាអ្វី មិនសងអ្វី មិនធ្វើអ្វីនោះទេ។ វាគ្រាន់តែទទួលបាន ទទួលយក លូកចាប់បាន និងក្រសោបអំណោយទានការរាប់ជាសុចរិតដែលប្រកបដោយព្រះគុណដែលព្រះគ្រីស្ទប្រទានឲ្យប៉ុណ្ណោះ។[២៤]

នេះមានន័យថា មិនមែនសេចក្តីជំនឿនោះផ្ទាល់ (ឬសូម្បីតែគោលលទ្ធិអំពីការរាប់ជាសុចរិតដោយសារសេចក្តីជំនឿ) ដែលសង្គ្រោះយើងនោះទេ។ ប៉ុន្តែព្រះគ្រីស្ទសង្គ្រោះយើងទេ ហើយសេចក្តីជំនឿគឺជាឧបករណ៍ដែលនាំឲ្យយើងទទួលយកព្រះគ្រីស្ទ។ បណ្ឌិត ចន កាលវិន និយាយថា «ក្រៅពីសេចក្តីសុចរិតបានពីការប្រព្រឹត្ត នោះយើងបានរាប់ជាសុចរិតដោយសារសេចក្តីជំនឿដោយការលូកចាប់យកសេចក្តីសុចរិតរបស់ព្រះគ្រីស្ទតាមរយៈសេចក្តីជំនឿ ហើយយើងស្លៀកសេចក្តីសុចរិតនោះ នោះយើងបានរាប់ជាសុចរិតនៅចំពោះព្រះ មិនមែនជាមនុស្សមានបាបទៀតនោះទេ។

ថ្វីបើគម្ពីររ៉ូម ៣ មិនប្រើពាក្យ ការរាប់ជាសុចរិតគឺ «ដោយសារសេចក្តីជំនឿតែមួយ» នេះគឺជាអ្វីដែលបទគម្ពីររ៉ូម ៣ កំណត់សេចក្តី ជាពិសេសនៅចុងក្រោយ៖«ដូច្នេះតើសេចក្តីអួតអាងនៅឯណា?គឺត្រូវលើកចោលហើយតើច្បាប់ណាដែលលើកចោលនោះតើជាច្បាប់ខាងឯការប្រព្រឹត្តឬ? មិនមែនទេគឺជាច្បាប់ខាងឯសេចក្តីជំនឿវិញទេតើដ្បិតយើងខ្ញុំអាងថា

មនុស្សបានរាប់ជាសុចរិតដោយសារសេចក្តីជំនឿគឺមិនមែនដោយការប្រព្រឹត្តតាមក្រិត្យវិន័យទេ» (រ៉ូម ៣:១៩-២០ ប្រៀបធៀប កាឡាទី ២:១៦)។

បើសិនយើងបានរាប់ជាសុចរិតដោយការប្រព្រឹត្ត ឬដោយសេចក្តីជំនឿបន្ថែមការប្រព្រឹត្ត នោះសេចក្តីសង្គ្រោះនឹងជាអ្វីមួយដែលយើងត្រូវអួតអំពីហើយ (សូមមើលអេភេសូរ ២:៩)។ ប៉ុន្តែគ្មានអ្នកណាម្នាក់នឹងអាចអួតថាគាត់នឹងទៅស្ថានសួគ៌ដោយការប្រព្រឹត្តរបស់គាត់ផ្ទាល់បានទេ។ យើងបានរាប់ជាសុចរិតដោយផ្អែកលើជីវិតឥតខ្ចោះនិងការសុគតជាយញ្ញបូជារបស់ព្រះយេស៊ូវគ្រីស្ទ ហើយយើងមិនចាំបាច់ធ្វើអ្វីលើសពីគ្រាន់តែជឿនោះឡើយ។ នេះជាការដកស្រង់ពីសេចក្តីថ្លែងការណ៍អំពីសេចក្តីជំនឿរបស់ក្រុមចម្រុះដំណឹងល្អ «យើងជឿថាព្រះទ្រង់រាប់ជាសុចរិតហើយញែកជាបរិសុទ្ធដល់អស់អ្នកណាដែលមានជំនឿលើព្រះយេស៊ូវដោយសារព្រះគុណទ្រង់»។

## *គោលដៅរបស់ការរាប់ជាសុចរិត៖ ការប្រព្រឹត្តល្អដើម្បីសិរីរុងរឿងរបស់ព្រះ*

អ្នកខ្លះគិតថា សាវ័កយ៉ាកុបសរសេរផ្ទុយនឹងសេចក្តីពិតថាព្រះអង្គរាប់យើងជាសុចរិតដោយសេចក្តីជំនឿតែមួយគត់។ យ៉ាកុបសរសេរថា «មនុស្សបានរាប់ជាសុចរិតមិនមែនដោយសារតែសេចក្តីជំនឿប៉ុណ្ណោះទេ គឺដោយសារការប្រព្រឹត្តដែរ» (យ៉ាកុប ២:២៤)។ តែអ្វីដែលយ៉ាកុបកំពុងនិយាយគឺដូចនេះ «មនុស្សដែលបានរាប់ជាសុចរិតបានសំដែងភស្តុតាងបង្ហាញថាគេបានរាប់ជាសុចរិតដោយសារការប្រព្រឹត្តហើយមិនមែនដោយសារសេចក្តីជំនឿរបស់គាត់ប៉ុណ្ណោះទេ»។ ខុសពីប៉ុលដែលបានចង់ប្រឆាំងនឹងទស្សនៈដែលមានប្រជាប្រិយភាពដែលថា ពួកមនុស្សមានបាបអាចបានសង្គ្រោះដោយសារការប្រព្រឹត្តល្អ នោះយ៉ាកុបកំពុងពិភាក្សាតទល់នឹងទស្សនៈយល់ខុសដែលថាពួកអ្នកជឿមិនចាំបាច់ប្រព្រឹត្តល្អអ្វីទាំងអស់។ យើងពន្យល់អំពីភាពខុសគ្នារវាងពួកគាត់ទាំងពីរនៅក្នុងពាក្យទេវសាស្រ្តថា ប៉ុលបានកំពុងកែមនុស្សដែលចង់ធ្វើឲ្យការញែកជាបរិសុទ្ធជាផ្នែកមួយនៃមូលដ្ឋានគ្រឹះសម្រាប់ការរាប់ជាសុចរិតរបស់ពួកគេ តែយ៉ាកុបបានកំពុងកែមនុស្សដែលចង់បានព្រះអង្គរាប់គេជាសុចរិតដោយមិនចាំបាច់បានញែកជាបរិសុទ្ធ!

សម្រាប់យ៉ាកុបនិងប៉ុលផងដែរ «រាប់ជាសុចរិត» មានន័យថា «ប្រកាសអ្នកណាម្នាក់ថាសុចរិត»។ ភាពខុសគ្នាគឺថា ប៉ុលបង្រៀនថា គឺជាព្រះដែលប្រកាសអ្នកជឿជាសុចរិត តែយ៉ាកុបបង្រៀនថា គឺជាការប្រព្រឹត្តរបស់អ្នកជឿដែលប្រកាសគាត់ជាសុចរិតដោយការបង្ហាញថាគាត់មានសេចក្តីជំនឿពិតប្រាកដ។ សេចក្តីបង្រៀនរបស់សាវ័កទាំងពីរដូចសេចក្តីបង្រៀនរបស់ បណ្ឌិត ចន កាលវិន ដែលថា «ព្រះជាម្ចាស់បានរាប់យើងជាសុចរិតដោយជំនឿតែមួយគត់ ប៉ុន្តែសេចក្តីជំនឿដែលរាប់ជាសុចរិតមិនមែនតែមួយនោះទេ(គឺមានការប្រព្រឹត្តផងដែរ)»។[២៦] សេចក្តីជំនឿនិងការប្រព្រឹត្តមិនរួមគ្នាបង្កើតការរាប់ជាសុចរិតនោះទេ (សេចក្តីជំនឿ + ការប្រព្រឹត្ត>>ការរាប់ជាសុចរិត)។ តែសេចក្តីជំនឿនាំឲ្យព្រះអង្គរាប់យើងជាសុចរិតហើយបង្កើតការប្រព្រឹត្តល្អ (សេចក្តីជំនឿ>>ការរាប់ជាសុចរិត+ការប្រព្រឹត្ត)។

យើងនិយាយសេចក្តីបង្រៀននេះតាមរបៀបផ្សេង សេចក្តីជំនឿតែមួយគត់ដែលរាប់ជាសុចរិតគឺជាសេចក្តីជំនឿដែលមានការប្រព្រឹត្ត។ នេះពន្យល់អំពីមូលហេតុដែលសេចក្តីថ្លែងការណ៍អំពីការរាប់ជាសុចរិតរបស់ក្រុមចម្រុះដំណឹងល្អបញ្ចប់ដោយនិយាយថា «យើងជឿថាការខិតខំក្នុងការស្តាប់បង្គាប់ទាំងលក្ខណៈជាសាធារណៈនិងលក្ខណៈជាបុគ្គលគឺហូរចេញមកពីការរាប់ជាសុចរិតដែលឥតបង់ថ្លៃនេះ»។ សេចក្តីពិតតាមព្រះគម្ពីរអំពីការរាប់ជាសុចរិតមិនប្រឆាំងនឹងការប្រព្រឹត្តល្អនោះទេ ប៉ុន្តែការពិតវាបង្កើតការប្រព្រឹត្តល្អទាំងនោះវិញ។ ការរាប់ជាសុចរិតរបស់យើងទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងការញែកជាបរិសុទ្ធរបស់យើង។

ទាក់ទងនឹងការរាប់ជាសុចរិត ការប្រព្រឹត្តរបស់ព្រះគ្រីស្ទនិងការប្រព្រឹត្តរបស់យើងគឺដាច់ដោយឡែកពីគ្នា។ ដូចជាប៉ុលនិយាយក្នុងសំបុត្រកាឡាទីថា «មនុស្សមិនបានរាប់ជាសុចរិតដោយប្រព្រឹត្តតាមក្រឹត្យវិន័យនោះឡើយ គឺដោយសេចក្តីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទវិញ» (កាឡាទី ២:១៦)។ ដូច្នេះ ការរាប់ជាសុចរិតបានមកដោយការជឿទុកចិត្ត មិនមែន

ដោយការប្រព្រឹត្ត «តែចំណែកអ្នកដែលមិនធ្វើការសោះ គឺគ្រាន់តែជឿដល់ព្រះអង្គដែលទ្រង់ប្រោសឲ្យមនុស្សទមិលល្មើស បានសុចរិត នោះសេចក្តីជំនឿរបស់អ្នកនោះបានរាប់ទុកជាសេចក្តីសុចរិតវិញ» (រ៉ូម ៤:៥)។ ទាក់ទងនឹងការរាប់ជាសុចរិត ព្រះគម្ពីរដាក់សេចក្តីជំនឿនិងការប្រព្រឹត្តឲ្យប្រឆាំងគ្នាទៅវិញទៅមក។ បើសិនព្រះអង្គរាប់យើងជាសុចរិតដោយសារសេចក្តីជំនឿ នោះវាមិនដោយសារការប្រព្រឹត្តនោះទេ។ ដោយការបង្រៀនរបៀបនេះ នោះព្រះគម្ពីរពិតជាកំពុងនិយាយថា ការរាប់ជាសុចរិតគឺដោយសារសេចក្តីជំនឿតែមួយគត់។ ពីព្រោះ បើសិនការរាប់ជាសុចរិតមិនដោយសារការប្រព្រឹត្ត នោះវាត្រូវតែបានមកដោយសារសេចក្តីជំនឿតែមួយប៉ុណ្ណោះ។

មានហេតុផលសំខាន់មួយសម្រាប់ភាពដោយឡែកពីគ្នារវាងសេចក្តីជំនឿនិងការប្រព្រឹត្ត ដែលជាហេតុផលមួយជួយយើងឲ្យយល់អំពីគោលបំណងនៃការរាប់ជាសុចរិតរបស់យើងនៅក្នុងផែនការរបស់ព្រះ។ បើសិនការរាប់ជាសុចរិតបានមកដោយសារតែសេចក្តីជំនឿតែមួយគត់ នោះរបៀបរាប់ជាសុចរិតតាមព្រះគម្ពីរធានាថា សិរីល្អទាំងអស់ត្រូវថ្វាយដល់ព្រះតែមួយអង្គទ្រង់។ បើសិនយើងបានរាប់ជាសុចរិតដោយសារការងារសង្គ្រោះរបស់ព្រះយេស៊ូវជាជាងដោយសារការប្រព្រឹត្តផ្ទាល់ខ្លួនរបស់យើង នោះការសរសើរតម្កើងទាំងអស់សម្រាប់សេចក្តីសង្គ្រោះរបស់យើងត្រូវថ្វាយដល់ទ្រង់ មិនមែនដល់យើងនោះទេ។ ដូច្នេះ ដូចជាផ្នែកផ្សេងៗទាំងអស់នៃដំណឹងល្អ គឺគោលដៅរបស់ការរាប់ជាសុចរិតគឺជាសិរីល្អរបស់ព្រះ។

## *ពួកអ្នកទទួលបានការរាប់ជាសុចរិត៖ មនុស្សដូចជាយើង*

ការបញ្ជាក់ដ៏ល្អបំផុតមួយនៃសេចក្តីពិតអំពីការរាប់ជាសុចរិតតាមព្រះគម្ពីរមកពីសៀវភៅស្តីពីគោលជំនឿសំខាន់ៗតាមរបៀបសំនួរចម្លើយ Heidelberg Catechism ដែលសួរថា «តើអ្នកសុចរិតនៅចំពោះព្រះបានយ៉ាងដូចម្តេច?» (សំនួរ ៦០)។ ចម្លើយគឺ៖

> ដោយសារសេចក្តីជំនឿពិតប្រាកដក្នុងព្រះយេស៊ូវគ្រីស្ទតែប៉ុណ្ណោះ។ ថ្វីបើបញ្ញាចិត្តរបស់ខ្ញុំចោទប្រកាន់ខ្ញុំថា ខ្ញុំបានធ្វើបាបទាស់នឹងក្រឹត្យវិន័យទាំងអស់របស់ព្រះ ហើយមិនបានរក្សាតាមក្រឹត្យវិន័យណាមួយនោះទេ ហើយខ្ញុំនៅតែឆាប់ទោទន់ទៅរកការអាក្រក់គ្រប់យ៉ាង។ ប៉ុន្តែព្រះប្រទានឲ្យខ្ញុំនូវគុណប្រយោជន៍នៃការសុគតជំនួសដ៏ឥតខ្ចោះរបស់ព្រះគ្រីស្ទ ប្រទានសេចក្តីសុចរិតនិងសេចក្តីបរិសុទ្ធរបស់ទ្រង់ដល់ខ្ញុំដូចជាខ្ញុំមិនដែលបានធ្វើបាបណាមួយសោះអញ្ចឹង គឺបានបំពេញរាល់ការស្តាប់បង្គាប់ទាំងអស់ដែលព្រះគ្រីស្ទបានប្រព្រឹត្តជំនួសខ្ញុំ ដោយគ្រាន់តែខ្ញុំទទួលយកការទាំងនេះដោយចិត្តជឿប៉ុណ្ណោះ។

សូមកត់សំគាល់ថា បើសិនការរាប់ជាសុចរិតបានមកតាមរយៈសេចក្តីជំនឿ នោះខ្លួនយើងត្រូវតែជឿលើព្រះយេស៊ូវគ្រីស្ទដោយផ្ទាល់ខ្លួនដើម្បីបានរាប់ជាសុចរិត។ ការរាប់ជាសុចរិតមិនគ្រាន់តែជាគោលការណ៍ទូទៅអំពីផ្លូវនៃសេចក្តីសង្គ្រោះនោះទេ តែវាគឺជាការត្រាស់ហៅឲ្យធ្វើការប្តេជ្ញាសេចក្តីជំនឿផ្ទាល់ខ្លួនចំពោះព្រះគ្រីស្ទផងដែរ ពីព្រោះយើងនឹងត្រូវបានផ្តន្ទាទោសបើសិនយើងគ្មានទ្រង់នោះ។ ការពិត ព្រះគម្ពីរព្រមានថា «តែអ្នកណាដែលមិនជឿវិញ នោះត្រូវមានទោសហើយពីព្រោះមិនបានជឿដល់ព្រះនាមនៃព្រះរាជបុត្រាតែមួយរបស់ព្រះ» (យ៉ូហាន ៣:១៨)។ ប៉ុន្តែខគម្ពីរដដែលនេះក៏សន្យាថា «ឯអ្នកណាដែលជឿដល់ទ្រង់ នោះមិនជាប់មានទោសទេ»។ ដូច្នេះ បើសិនយើងបានរាប់ជាសុចរិតហើយមិនជាប់មានទោស នោះយើងត្រូវតែដាក់សេចក្តីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ។

ព្រះប្រទានការវិនិច្ឆ័យចុងក្រោយរបស់ព្រះ «បានសុចរិតនៅអស់កល្បជានិច្ច» មកក្នុងបទពិសោធន៍បច្ចុប្បន្នរបស់យើង។ «ដូច្នេះ ដោយព្រោះយើងបានរាប់ជាសុចរិតតាមរយៈសេចក្តីជំនឿ» នោះបទគម្ពីរនិយាយថា «យើងបានមេត្រីនឹងព្រះដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា» (រ៉ូម ៥:១)។ រឿងក្តីផ្តល់របស់យើងតាមផ្លូវច្បាប់របស់ព្រះត្រូវបានធ្វើសេចក្តីសម្រេចរួចរាល់ហើយ។ ព្រះបានទទួលយកយើងឥឡូវនេះនិងអស់កល្បជានិច្ចដោយយល់ដល់សិរីរុងរឿងរបស់ទ្រង់។ ថ្ងៃវិនិច្ឆ័យនឹងបញ្ជាក់ពីអ្វីដែលព្រះបានប្រកាសរួចរាល់ហើយថា «នៅជាន់នេះ អ្នកណាដែលនៅក្នុងព្រះយេស៊ូវ

គ្រីស្ទ នោះគ្មានទោសសោះ» (រ៉ូម ៨:១)។ អ្នកនិពន្ធកំណាព្យ លោក វីលៀម ខាវ៉ធឺ William Cowper មានអំណរដែលមកពីយើងបានរាប់ជាសុចរិតតាមរយៈសេចក្តីជំនឿ។ លោក ខាវ៉ធឺ បានរងទុក្ខដោយការធ្លាក់ទឹកចិត្តអស់ជាយូរ ហើយពេលមួយគាត់បានរស់នៅក្នុងសមាវសថាគាពេទ្យឆ្កួតក្នុងស្ថានភាពគួរឲ្យតក់ស្លុត។ ប៉ុន្តែ ថ្វីបើគាត់មានទារុណកម្មខាងរូបកាយនិងចិត្តក៏ដោយ ក៏ការរងទុក្ខធ្ងន់ធ្ងរបំផុតរបស់គាត់គឺខាងព្រលឹងវិញ្ញាណវិញ ពីព្រោះគាត់បានចាត់ទុកខ្លួនគាត់ជាមនុស្សបាបដែលជាប់មានទោស។ តែថ្ងៃមួយ លោក ខាវ៉ធឺបានរកឃើញថ្នាំព្យាបាលខាងព្រលឹងវិញ្ញាណរបស់គាត់នៅក្នុងសេចក្តីពិតនៃការរាប់ជាសុចរិតដោយសារសេចក្តីជំនឿតែមួយគត់។ គាត់បានប្រាប់រឿងរបស់គាត់ដូចនេះថា៖

> ពេលវេលាសប្បាយរីករាយដែលត្រូវដោះចំណងរបស់ខ្ញុំចេញហើយផ្តល់ឲ្យខ្ញុំនូវការចាប់ផ្តើមទទួលសេចក្តីមេត្តាករុណារបស់ព្រះដោយទទេនៅក្នុងព្រះគ្រីស្ទយេស៊ូវបានមកដល់ហើយ។ ខ្ញុំបានទំលាក់ខ្លួនក្នុងកៅអីមួយជិតបង្អួចក៏បានឃើញព្រះគម្ពីរនៅទីនោះ ហើយក៏អានដើម្បីអោយកំសាន្តចិត្តនិងសេចក្តីបង្រៀន។ ដំបូងខ្ញុំបានអានខគម្ពីរនៅក្នុងគម្ពីររ៉ូម ៣ ដែលនិយាយថា "តែដោយពឹងដល់ព្រះគុណទ្រង់ នោះបានរាប់ជាសុចរិតទទេដោយសារសេចក្តីប្រោសលោះដែលនៅក្នុងព្រះយេស៊ូវ ដែលព្រះបានតាំងទ្រង់ទុកជាទីសន្តោសប្រោស ដោយសារសេចក្តីជំនឿជឿដល់ព្រះលោហិតទ្រង់ សម្រាប់នឹងសំដែងឲ្យឃើញសេចក្តីសុចរិតរបស់ព្រះ" (រ៉ូម ៣:២៤-២៥)។ ភ្លាមៗនោះខ្ញុំបានទទួលកម្លាំងជឿ ហើយពន្លឺពេញរបស់ព្រះអាទិត្យនៃសេចក្តីសុចរិតបានចាំងជះមកលើខ្ញុំ។ ខ្ញុំបានមើលឃើញថាការធួននឹងបាបរបស់ទ្រង់គឺគ្រប់គ្រាន់សម្រាប់ខ្ញុំហើយ ការអត់ទោសរបស់ខ្ញុំនៅក្នុងព្រះលោហិត និងភាពពេញលេញនៃការរាប់ជាសុចរិតរបស់ទ្រង់។ ភ្លាមៗនោះខ្ញុំបានជឿហើយទទួលយកដំណឹងល្អ។[២៧]

អស់អ្នកដែលជឿនិងទទួលយកដំណឹងល្អអាចទទួលបានសេចក្តីសុចរិតដ៏ជាអំណោយទាន។ ដោយសារព្រះគុណដែលទទួលបានដោយទទេ នោះព្រះប្រទានការរាប់ជាសុចរិតពេញលេញដោយផ្អែកលើការងារធួននឹងបាបរបស់ព្រះយេស៊ូវគ្រីស្ទ។ អស់អ្នកដែលមានជំនឿលើព្រះយេស៊ូវគ្រីស្ទ នឹងបានរាប់ជាសុចរិតនៅចំពោះយុត្តិធម៌ដ៏អស់កល្បជានិច្ចរបស់ព្រះ។

## *កំណត់*

១. ខគម្ពីរយោងដែលត្រូវបានដកស្រង់ចេញពីព្រះគម្ពីរខ្មែរបរិសុទ្ធ (១៩៥៤).

២. Donald Smarto, Pursued: A True Story of Crime, Faith, and Family (Downers Grove, IL: InterVarsity, 1990), 105.

៣. Ibid., 105–6.

៤. Ibid., 119–20.

៥. James Buchanan, The Doctrine of Justification (1867; repr., Grand Rapids, MI: Baker, 1955), 222.

៦. Leon Morris, The Apostolic Preaching of the Cross, 3rd ed. (Grand Rapids, MI: Eerdmans, 1965), 251.

៧. John Calvin, Institutes of the Christian Religion, Library of Christian Classics 20–21, ed. John T. McNeill; trans. Ford Lewis Battles (Philadelphia: Westminster, 1960), 3.11.1.

៨. Thomas Cranmer, "Sermon on Salvation," in First Book of Homilies (1547; repr. London: SPCK, 1914), 25–26.

໙. Martin Luther, What Luther Says: A Practical In-Home Anthology for the Active Christian, ed. Ewald M. Plass (St. Louis, MO: Concordia, 1959), 705, 715.

໑໐. Ibid., 704.

໑໑. Morris, Apostolic Preaching of the Cross, 260.

໑໒. Thomas Cranmer, quoted in Edmund P. Clowney, "The Biblical Doctrine of Justification by Faith," in Right with God: Justification in the Bible and the World, ed. D. A. Carson (Exeter: Paternoster, 1992), 17.

໑໓. Thomas Chalmers, quoted in Donald Grey Barnhouse, The Invisible War (Grand Rapids, MI: Zondervan, 1965), 116.

໑໔. John R. W. Stott, The Cross of Christ (Downers Grove, IL: InterVarsity, 1986), 190.

໑໕. Ibid., 190.

໑໖. Ibid., 202.

໑໗. Smarto, Pursued, 122.

໑໘. Calvin, Institutes, 3.11.10.

໑໙. Anthony A. Hoekema, Saved by Grace (Grand Rapids, MI: Eerdmans, 1989), 178.

໒໐. Pieter W. Van Der Horst, "Jewish Funerary Inscriptions," Biblical Archaeology Review 18:5 (1992): 55.

໒໑. Martin Luther, Lectures on Galatians, Luther's Works, ed. and trans. Jaroslav Pelikan (St. Louis, MO: Concordia, 1963), 26:126.

໒໒. Martin Luther, quoted in James Montgomery Boice, The Minor Prophets: An Expositional Commentary, 2 vols. (Grand Rapids, MI: Kregel, 1996), 2:91–92.

໒໓. "Justification," in Evangelical Dictionary of Theology, 2nd ed., ed. Walter A. Elwell (Grand Rapids, MI: Baker, 2001), 646.

໒໔. J. C. Ryle, Justified!, Home Truths, Second Series (London: S. W. Partridge, 1854–71), 12.

໒໕. Calvin, Institutes, 3.11.2.

໒໖. John Calvin, "Antidote to the Canons of the Council of Trent," in Tracts and Treatises in Defense of the Reformed Faith, trans. Henry Beveridge (1851; repr., Grand Rapids, MI: Eerdmans, 1958), 3:152.

໒໗. William Cowper, quoted in James Montgomery Boice, Romans, 4 vols. (Grand Rapids, MI: Baker, 1991), 1:372.